ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៣១ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I - ខុទ្ទកាល័យរដ្ឋសភា

ច្បាប់

២១-២-៩៥ ច្បាប់ស្តីពីការផ្តល់សច្ចាប័ន លើកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៤ រវាងព្រះរាជាណាចក្រកម្ពុជា និង សមាគមអភិវឌ្ឍន៍អន្តរជាតិ ។ ១៥១១

II - ខុទ្ទកាល័យព្រះមហាក្សត្រ

១ - ព្រះរាជក្រម

១៣-២-៩៥ ព្រះរាជក្រម លេខ នស/រកម/០៣៩៥/០១ ច្បាប់ស្តីពីការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៤ រវាងព្រះរាជាណាចក្រកម្ពុជា និងសមាគមអភិវឌ្ឍន៍អន្តរជាតិ ១៥១២

២ - ព្រះរាជក្រឹត្យ

២៣-៨-៩៥ ព្រះរាជក្រឹត្យ លេខ នស/រកត/០៨៩៥/៦១ ១៥៧១

III - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

២៤-៨-៩៥ អនុក្រឹត្យលេខ ៦៦ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំខ្សែក្រវាត់ បៃតង ជុំវិញរាជធានីភ្នំពេញ ១៥៧២
២៤-៨-៩៥ អនុក្រឹត្យលេខ ៩៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥៧៤
២៤-៨-៩៥ អនុក្រឹត្យលេខ ៩៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥៧៦
២៤-៨-៩៥ អនុក្រឹត្យលេខ ៩៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥៧៧
២៥-៨-៩៥ អនុក្រឹត្យលេខ ៩៧ អនក្រ.តត ស្តីពីការអោយចូលនិវត្តន៍មន្ត្រីរាជការ ១៥៧៨

២៩–៨–៩៥	អនុក្រឹត្យលេខ ៩៨ អនក្រ. តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១៥៨០
២៩–៨–៩៥	អនុក្រឹត្យលេខ ៩៩ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១៥៨១
២៩–៨–៩៥	អនុក្រឹត្យលេខ ១០០ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១៥៨២
២៩–៨–៩៥	អនុក្រឹត្យលេខ១០១ អនក្រ. តត ស្តីពីការតែងតាំងទីប្រឹក្សា និងជំនួយការឯកឧត្តមរដ្ឋមន្ត្រី និងឯកឧត្តមរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ	១៥៨៣

២ - សេចក្តីសំរេច

៣០–៨–៩៥	សេចក្តីសំរេចលេខ ៥៩ សសរ ស្តីពីការផ្ទេរសិទ្ធិ	១៥៨៤
៣០–៨–៩៥	សេចក្តីសំរេចលេខ ៦០ សសរ ស្តីពីការផ្ទេរសិទ្ធិ	១៥៨៥
៣១–៨–៩៥	សេចក្តីសំរេចលេខ ៦១ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំតាំងពិពរណ៍ ស្តីពីសមិទ្ធផលរបស់រាជរដ្ឋាភិបាល	១៥៨៦

IV - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

២៤–៨–៩៥	ប្រកាសលេខ ៣០៨ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន	១៥៨៨
៣១–៨–៩៥	ប្រកាសលេខ ៣១៣ សហវ. ថ ស្តីពីការណែនាំរៀបចំគំរោងថវិការដ្ឋឆ្នាំ ១៩៩៦	១៥៩០

២ - ធនាគារជាតិ នៃ កម្ពុជា

ប្រកាស

២៥–៨–៩៥	ប្រកាសលេខ ធ ៩៩៥ -១២០ ប្រក ស្តីពីការប្រគល់សិទ្ធិចុះហត្ថលេខាលេខប្រតិវេទន៍ នៃការនាំចេញ នាំចូលរូបិយប័ណ្ណ និងលោហធាតុត្បូងថ្មមានតម្លៃ	១៥៩៤

៣ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

២៥-៨-៩៥	ប្រកាសលេខ ៦៧៥ បុល.ប្រក ស្ដីពីការផ្ទេរ និងសម្រួលភារកិច្ចមន្ត្រីរាជការ	១៥៩៥
២៥-៨-៩៥	ប្រកាសលេខ ៦៧៦ ផក.ប្រក អនុញ្ញាតអោយលោក វិញ ទ្រី ជនជាតិខ្មែរ បើកដំណើរការរោងឧស្សាហកម្មផលិតប្រេងរំអិល «COSMIC»	១៥៩៧
២៥-៨-៩៥	ប្រកាសលេខ ៦៧៧ ផក.ប្រក អនុញ្ញាតអោយលោក ពេញ សាយ ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីន ផលិតទឹកកកដើម	១៥៩៨
២៥-៨-៩៥	ប្រកាសលេខ ៦៧៨ ផក.ប្រក អនុញ្ញាតអោយលោក គង់ វាសនា ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កម្លាំង ៨០ សេះ	១៥៩៨
២៥-៨-៩៥	ប្រកាសលេខ ៦៧៩ ផក.ប្រក អនុញ្ញាតអោយលោក ស៊ឹម កុក ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កម្លាំង ៨០ សេះ	១៥៩៨
២៥-៨-៩៥	ប្រកាសលេខ ៦៨០ ផក.ប្រក អនុញ្ញាតអោយលោក សុខ សេង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម	១៥៩៩
២៥-៨-៩៥	ប្រកាសលេខ ៦៨១ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ពួង ឡាគន្ធ ជនជាតិខ្មែរ បន្តដំណើរការសិប្បកម្មផលិតថ្នាំលាបសក់	១៥៩៩
២៨-៨-៩៥	ប្រកាសលេខ ៦៨៩ បុល.ប្រក ស្ដីពីការតែងតាំងមន្ត្រីរាជការ	១៦០០

៤ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

២៦-៨-៩៥	ប្រកាសលេខ ១៩៣/៩៥ ពម.ប្រក ស្ដីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង	១៦០១
២៦-៨-៩៥	ប្រកាសលេខ ១៩៥/៩៥ ពម.ប្រក ស្ដីពីការទទួលស្គាល់លោក ប៉ាង ឆន ជាមន្ត្រីរបស់ក្រសួងពត៌មាន	១៦០២

៣០–៨–៩៥ ប្រកាសលេខ ២០៨/៩៥ ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង ១៦០៣

៥ - និស្ស័ការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

២៨–៨–៩៥ ប្រកាសលេខ ១៥២ ប្រក.វវស.បុ ស្តីពីការផ្ទេរក្របខ័ណ្ឌ ១៦០៥

៦ - និស្ស័ការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

២៨–៨–៩៥ ប្រកាសលេខ ១៣៤០ អយក.ប្រក ស្តីពីការផ្តាច់សាលាបឋមសិក្សា ស្រែពោធិ ឧបសម្ព័ន្ធសាលាបឋមសិក្សា ស្ទឹងត្រែង អោយទៅជាសាលាបឋមសិក្សា ឃុំ ស្រះឫស្សី ១៦០៦

២៨–៨–៩៥ ប្រកាសលេខ ១៣៤១ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ មកជាសាលាបឋមសិក្សាពេញលក្ខណៈ ១៦០៧

២៨–៨–៩៥ ប្រកាសលេខ ១៣៤២ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ មកជាសាលាបឋមសិក្សាពេញលក្ខណៈ ១៦០៩

២៨–៨–៩៥ ប្រកាសលេខ ១៣៤៣ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ មកជាសាលាបឋមសិក្សាពេញលក្ខណៈ ១៦១០

២៨–៨–៩៥ ប្រកាសលេខ ១៣៤៤ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ មកជាសាលាបឋមសិក្សាពេញលក្ខណៈ ១៦១២

៣១–៨–៩៥ ប្រកាសលេខ ១៣៥៣ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ មកជាសាលាបឋមសិក្សាពេញលក្ខណៈ ១៦១៤

៧ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិដ្ឋាន

ប្រកាស

២២–៨–៩៥	ប្រកាសលេខ ៥១១ ប្រក.បស្ក ស្ដីពីការទទួលស្គាល់និង ប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ	១៦១៦

៨ - ទីស្ដីការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

២៦–៨–៩៥	ប្រកាសលេខ ១០៧ បទ.ប្រក ស្ដីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រី បុគ្គលិករាជការ	១៦១៧

៩ - ទីស្ដីការ ក្រសួងធម្មការ និង សាសនា

សេចក្ដីសំរេច

២៤–៨–៩៥	សេចក្ដីសំរេចលេខ ១៧៣/៩៥ កធស ស្ដីពីការទទួលស្គាល់ « ក្រុមប្រឹក្សាបរិស័ទគ្រិស្ទ នៃគណនិកាយសេវែនដេយ អាត់វេនទីស្ទ » នៅព្រះរាជាណាចក្រកម្ពុជា	១៦១៨

៧ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិដ្ឋាន

ប្រកាស

២២-៨-៩៥	ប្រកាសលេខ ៥១១ ប្រក.បស្ថ ស្តីពីការទទួលស្គាល់និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	១៦១៦

៨ - ទីស្តីការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

២៦-៨-៩៥	ប្រកាសលេខ ១០៧ បទ.ប្រក ស្តីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រី បុគ្គលិករាជការ	១៦១៧

៩ - ទីស្តីការ ក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

២៤-៨-៩៥	សេចក្តីសំរេចលេខ ១៧៣/៩៥ កធស ស្តីពីការទទួលស្គាល់ « ក្រុមប្រឹក្សាបរិសុទ្ធគ្រិស្ទ នៃគណនិកាយសេវ៉េនដេយ អាត់វ៉េនទីស្ទ » នៅព្រះរាជាណាចក្រកម្ពុជា	១៦១៨

I-ខុទ្ទកាល័យរដ្ឋសភា

ច្បាប់

ស្តីពី

ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍

ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៤

រវាង

ព្រះរាជាណាចក្រកម្ពុជា និង សមាគមអភិវឌ្ឍន៍អន្តរជាតិ.

មាត្រា ១ : ផ្តល់សច្ចាប័នទៅលើកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ ដែលរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ខ្ចីពីសមាគមអភិវឌ្ឍន៍អន្តរជាតិនូវទឹកប្រាក់ចំនួន SDR ដប់មួយលានប្រាំមួយរយពាន់ (SDR 11.600.000) សមមូលនឹង USD ដប់ប្រាំពីរលានពីររយពាន់ (USD17.200.000) តាមឥណទានលេខ ២៦៦៤HK ដើម្បីយកមកបំរើគំរោងជំនួយការបច្ចេកទេស ។

មាត្រា ២ : ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ នាសម័យប្រជុំវិសាមញ្ញនីតិកាលទី ១ ។

ភ្នំពេញ,ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រធានរដ្ឋសភា

ហត្ថលេខា និងត្រា

ជា ស៊ីម

II-ខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

ព្រះរាជក្រមលេខ នស/រកម/០៣៩៥/០១

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

ទ្រង់បានយល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំង ពីរ ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដោយគណៈរដ្ឋមន្ត្រីយល់ព្រមផង តាមរយៈការប្រជុំពេញអង្គថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងអំពីឥណទានអភិវឌ្ឍន៍ដែលបានស្រុះស្រួលគ្នា នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៩៤ រវាងព្រះរាជាណាចក្រកម្ពុជា និងសមាគមអន្តរជាតិអភិវឌ្ឍន៍ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៤

រវាង

ព្រះរាជាណាចក្រកម្ពុជា និងសមាគមអភិវឌ្ឍន៍អន្តរជាតិ

មាត្រា ១ :ផ្តល់សច្ចាប័នទៅលើកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ ដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ចីពីសមាគមអភិវឌ្ឍន៍អន្តរជាតិនូវទឹកប្រាក់ចំនួន SDR ដប់មួយលានប្រាំមួយរយពាន់ (SDR ១១.៦០០០.០០០) សមមូលនឹង USD ដប់ប្រាំពីរលានពីររយពាន់ (USD១៧.២០០.០០០) តាមឥណទានលេខ ២៦៦៤HK ដើម្បីយកមកបំរើគំរោងជំនួយការបច្ចេកទេស ។

មាត្រា ២ : ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ — **នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២ — **ហ៊ុន សែន**

បានបង្គំទូលថ្វាយ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ១៦ ធ្នូ ឆ្នាំ ១៩៩៤

សមាគមអភិវឌ្ឍន៍អន្តរជាតិ
វិថីលេខ ១៨១៨ H, N. W
វ៉ាស៊ីនតោន ឌីស៊ី ២០៤៣៣
សហរដ្ឋអាមេរិក

យោង : ឥណទានលេខ ២៦៦៤ KH
(គំរោងជំនួយការបច្ចេកទេស)
ផ្នែក ៩.០២ នៃល័ក្ខខណ្ឌទូទៅ
និន្នន័យហិរញ្ញវត្ថុ និង សេដ្ឋកិច្ច

អស់លោក ជាទីគោរព !

អនុលោមតាមឥណទានសំរាប់ព្រះរាជាណាចក្រកម្ពុជា ត្រូវនឹងទឹកប្រាក់ជារូបិយវត្ថុផ្សេងៗគ្នាសមមូលនឹង ១១.៦០០.០០០ SRD សំរាប់គំរោងជំនួយការបច្ចេកទេស តាងនាមព្រះរាជាណាចក្រកម្ពុជា ខ្ញុំមានកិត្តិយសសូមជំរាបអស់លោកដូចតទៅ :

១–យើងយល់ច្បាស់ និង ឯកភាពថា ក្នុងគោលបំណងទាំងឡាយបានចែងក្នុងផ្នែកនៃ ៩.០២ លក្ខខ័ណ្ឌទូទៅដែលអាចអនុវត្តបានចំពោះឥណទានអភិវឌ្ឍន៍ ព្រះរាជាណាចក្រកម្ពុជា ត្រូវបានសំណូមពរដោយសមាគមអោយធ្វើរបាយការណ៍ថ្មី «កិច្ចសន្យាបំណុលថ្មី» (ដូចបានបញ្ជាក់ក្នុងរបាយការណ៍ ស្តីពីបំណុលរបស់ធនាគារ ចុះខែ មករា ឆ្នាំ ១៩៨៩) អោយបានមុន ៣០ថ្ងៃ បន្ទាប់ពីដំណាច់ត្រីមាស ក្នុងកំឡុងពេលដែលបំណុលបានកើតឡើងរួចហើយ និង របាយការណ៍ «ទំនាក់ទំនងក្រោមរូបភាពបំណុល» (ដូចបានបញ្ជាក់) អោយបានមុនថ្ងៃទី ៣១ មីនា នៃឆ្នាំ ។

២–សូមបញ្ជាក់ថា គ្មានកំហុសណាមួយកើតឡើងក្នុងការអនុវត្តន៍បំណុលសាធារណៈក្រៅប្រទេស ។ យើងជឿជាក់ថា ក្នុងការធ្វើឥណទាន សមាគមត្រូវផ្អែកតាមរបាយការណ៍ ឬក៏ផ្អែកតាមលិខិតនេះ ។

ព្រះរាជាណាចក្រកម្ពុជា
ដោយ **គាត ឈន់**
តំណាងរាជរដ្ឋាភិបាល

ឥណទានលេខ ២៦៦៤ KH

កិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍

«គំរោងជំនួយការ—បច្ចេកទេស»

រវាង

ព្រះរាជាណាចក្រកម្ពុជា

និង

សមាគម អភិវឌ្ឍន៍អន្តរជាតិ

ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៤

កិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍

កិច្ចព្រមព្រៀងចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៤ រវាងព្រះរាជាណាចក្រកម្ពុជា ហៅកាត់ «**អ្នកខ្ចី**» និងសមាគមអភិវឌ្ឍន៍អន្តរជាតិ ហៅកាត់ «**សមាគម**» ។

«ក» អ្នកខ្ចីមានសោមនស្សរីករាយលើលទ្ធភាព និង អាទិភាព នៃគំរោងដែលបានពិពណ៌នាក្នុងកម្មវិធី ២ នៃកិច្ចព្រមព្រៀងនេះ បានស្នើសុំដល់សមាគមរួមវិភាគទានផ្នែកហិរញ្ញវត្ថុនៃគំរោង

«ខ» សមាគមបានឯកភាពពង្រីកឥណទានដល់អ្នកខ្ចីលើមូលដ្ឋានផ្សេងៗ តាមប្រការ និង លក្ខខ័ណ្ឌទាំងឡាយ ដែលបានចែងក្នុងកិច្ចព្រមព្រៀង ។

<u>ភាគីទាំងសងខាងបានឯកភាពដូចខាងក្រោម</u> :

មាត្រា I

លក្ខខ័ណ្ឌទូទៅ និយមន័យ

ផ្នែក ១.០១ : លក្ខខ័ណ្ឌទូទៅ អនុវត្តលើកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍របស់សមាគម ចុះថ្ងៃទី ០១-០១-៨៥ ត្រង់ឃ្លាចុងបង្អស់នៃផ្នែក ៣.០២ ដែលបានលុបចោលលក្ខខ័ណ្ឌទូទៅបង្កើតបានជាកិច្ចព្រមព្រៀងនេះទាំងស្រុង ។

ផ្នែក ១.០២ : លើកលែងតែមានសំណូមពរជាក់ស្តែងផ្សេង ។ ប្រការជាច្រើនដែលបានកំណត់ក្នុងលក្ខខ័ណ្ឌទូទៅ និង ក្នុងបុព្វកថា នៃកិច្ចព្រមព្រៀងដែលមានន័យទាក់ទងព្រមទាំងមានបន្ថែមប្រការដែលមានន័យដូចខាងក្រោម :

ក–«គអក» មានន័យថា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានបង្កើតឡើងផ្អែកតាមច្បាប់វិនិយោគទុនរបស់អ្នកខ្ចី នៃ «ព្រះរាជាណាចក្រកម្ពុជា» មានប្រសិទ្ធភាពអនុវត្តនៅថ្ងៃទី ០៥ .៨. ១៩៩៤

ខ–«កច» មានន័យថា ក្រុមប្រឹក្សាអ្នកច្បាប់របស់អ្នកខ្ចីបង្កើតឡើងអនុលោមតាមអនុក្រឹត្យរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ១៣ ចុះថ្ងៃទី ១០–៣–១៩៩៤

គ–«គណ» មានន័យថា គណៈរដ្ឋមន្ត្រីរបស់អ្នកខ្ចីបង្កើតឡើងផ្អែកតាមក្រឹត្យ ចុះថ្ងៃទី ០១–១១–១៩៩៣

ឃ–«ឆ្នាំសារពើពន្ធ» មានន័យថា រយៈពេល ១២ ខែ ទាក់ទងទៅនឹងឆ្នាំសារពើពន្ធរបស់អ្នកខ្ចីណាមួយ ដែលរយៈកាលកំណត់ចាប់ផ្តើមពី ១ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ នៃ ឆ្នាំ ប្រតិទិននីមួយៗ

ង–«គអក» មានន័យថា គណៈកម្មាធិការបច្ចេកទេសអន្តរក្រសួងផ្នែកកែទំរង់រដ្ឋបាល បង្កើតឡើងយោងតាមអនុក្រឹត្យលេខ ២៣ ចុះថ្ងៃទី ០៩ ឧសភា ឆ្នាំ ១៩៩៤

ច–«អកច» មានន័យថា អង្គភាពកែទំរង់ច្បាប់ត្រូវបានបង្កើតឡើងដោយអ្នកខ្ចី ក្នុងក្របខ័ណ្ឌក្រុមប្រឹក្សាអ្នកច្បាប់យោងតាមប្រការដែលបានចែងក្នុងផ្នែក ៣.០៥ «ក» នៃកិច្ចព្រមព្រៀងនេះ

ឆ–«សហវ» មានន័យថា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់អ្នកខ្ចី

ជ–«ពណ» មានន័យថា ក្រសួងពាណិជ្ជកម្មរបស់អ្នកខ្ចី

ឈ–«យធ» មានន័យថា ក្រសួងយុត្តិធម៌របស់អ្នកខ្ចី

ញ–«ធជក» មានន័យថា ធនាគារជាតិ នៃកម្ពុជារបស់អ្នកខ្ចី

ដ–«អគគ» មានន័យថា អង្គភាពគ្រប់គ្រងគំរោង បង្កើតឡើងដោយអ្នកខ្ចី ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អនុលោមតាមប្រកាសលេខ ២៨៩ ប្រក ចុះថ្ងៃទី ២៨ វិច្ឆិកា ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឋ–«ភ្នាក់ងារគំរោង» មានន័យថា ក្រសួងស្ថាប័ន និង ភ្នាក់ងារនានារបស់អ្នកខ្ចី ដែលមានភារកិច្ចជួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងការអនុវត្តន៍គំរោង ។ ភ្នាក់ងារគំរោងទាំងនេះត្រូវផ្អែកតាមឧបសម្ព័ន្ធក្នុងកម្មវិធី ២ របស់កិច្ចព្រមព្រៀងនេះ ។

ឌ–ផែនការអនុវត្តន៍គំរោងមានន័យថា ផែនការសំរាប់អនុវត្តគំរោងរបស់អ្នកខ្ចី ហើយត្រូវបានផ្អែកតាមក្នុងផ្នែក ៣.០១ (ខ) និង មានចែងក្នុងកម្មវិធី ៥ ក្នុងកិច្ចព្រមព្រៀង ។

ឍ–«គណនីពិសេស» មានន័យថា ជាគណនីដែលបានចែងក្នុងផ្នែក ២.០២ (ខ) របស់កិច្ចព្រមព្រៀង ។

មាត្រា II

ឥណទាន

ផ្នែក ២.០១ : សមាគមឯកភាពផ្តល់អោយអ្នកខ្ចី លើលក្ខខ័ណ្ឌ និង ប្រការទាំងឡាយដែលបានចែង ឬ តាមកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍នេះ លើចំនួនទឹកប្រាក់មួយជារូបិយវត្ថុផ្សេងៗគ្នាសមមូលនឹងចំនួន ដប់មួយលានប្រាំមួយរយពាន់

SDR «១១,៦០០,០០០ » ។

ផ្នែក ២.០២(ក) : ចំនួនទឹកប្រាក់នៃឥណទាន ដែលអាចដកគណនីឥណទាន អនុលោមតាមប្រការទាំងឡាយ ដែលបានចែងក្នុងកិច្ចព្រមព្រៀងឥណទាន សំរាប់យកមកចំណាយ ឬ ត្រូវបានចំណាយក្រោយពីបានឯកភាពពីសមាគមត្រូវគោរពតាម តំលៃសមហេតុផល របស់ទំនិញ សេវា ដែលត្រូវការរបស់គំរោងដូចបានចែងក្នុងកម្មវិធី ២ នៃកិច្ចព្រមព្រៀងព្រមទាំងត្រូវបានផ្តល់ហិរញ្ញប្បទានចេញពីចំនួនទឹកប្រាក់ នៃឥណទាន ។

(ខ) : ដើម្បីគោលដៅនៃគំរោង អ្នកខ្ចីត្រូវបើកគណនីពិសេសមួយ ជាដុល្លារអាមេរិកនៅធនាគារជាតិនៃកម្ពុជា លើលក្ខខ័ណ្ឌដ៏ប្រសើររបស់សមាគមដោយប្រព្រឹត្តទៅសមស្របរួមការពារទប់ទល់ការប៉ះប៉ូវរឹបអូស ។ ប្រាក់តំកល់ និងការទូទាត់តាមរយៈគណនីពិសេសនេះនឹងប្រព្រឹត្តទៅត្រឹមត្រូវតាមខ្លឹមសារដែលបានចែងក្នុងកម្មវិធី ៤ នៃកិច្ចព្រមព្រៀងនេះ ។

ផ្នែក ២.០៣ : កាលបរិច្ឆេទបញ្ចប់ឥណទានត្រូវបានគ្រោង នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០១ ឬ អាចក្រោយកាលបរិច្ឆេទនេះ យោលទៅលើសមាគម ។ សមាគមនឹងជូនដំណឹងស្តីពី កាលបរិច្ឆេទថ្មីដល់អ្នកខ្ចីអោយបានឆាប់រហ័ស ។

ផ្នែក ២.០៤(ក) : អ្នកខ្ចីត្រូវបង់ជូនសមាគម នូវបន្ទុកកិច្ចសន្យាតាមអត្រាមួយដែលកំណត់ដោយសមាគមលើចំនួនទឹកប្រាក់នៃឥណទានដែលមិនទាន់បានដកប្រើ នៅថ្ងៃទី ៣០ ខែ មិថុនា រៀងរាល់ឆ្នាំ ក៏ប៉ុន្តែអត្រានោះមិនអោយលើសពីពាក់កណ្តាល នៃមួយភាគរយក្នុងមួយឆ្នាំ ។

(ខ) : បន្ទុកកិច្ចសន្យាចាប់គិតពី ៦០ ថ្ងៃ (i) បន្ទាប់ពីកិច្ចព្រមព្រៀងចូលជាធរមានទៅទល់នឹងកាលកំណត់មួយដែលចំនួននោះ ត្រូវបានដកដោយអ្នកខ្ចីពីគណនីឥណទាន ឬត្រូវបានលុបចោល ។ (ii) និង តាមអត្រាកំណត់ក្នុងថ្ងៃទី ៣០ មិថុនា ក្រោយពេលកិច្ចព្រមព្រៀងចូលជាធរមានភ្លាមៗ ឬ តាមអត្រាផ្សេងទៀតជាបន្តបន្ទាប់ យោងតាមកថាខ័ណ្ឌ ក ខាងលើ ។ អត្រាដែលកំណត់ នៅថ្ងៃទី ៣០ មិថុនា នៃឆ្នាំនីមួយៗ ត្រូវបានចាប់អនុវត្តពីកាលបរិច្ឆេទទូទាត់បន្ទាប់នៃឆ្នាំនោះ ដូចដែលបានបញ្ជាក់ក្នុងផ្នែក ២.០៦ នៃកិច្ចព្រមព្រៀងនេះ។

(គ): អ្នកខ្ចីត្រូវទូទាត់សងបន្ទុកកិច្ចសន្យា (i) តាមទីកន្លែងដែលសមាគម

សំណូមពរ (ii) ដោយគ្មានព្រំដែនលើប្រភេទចាប់បង្ខំណាមួយ (iii) ហើយដោយរូបិយប័ណ្ណជាក់លាក់ក្នុងកិច្ចព្រមព្រៀងនេះ ដើម្បីគោលបំណងក្នុងផ្នែក ២.០៤ នៃលក្ខខ័ណ្ឌទូទៅទាំងឡាយ ឬ រូបិយប័ណ្ណផ្សេងទៀតដែលយកជាការបាន ឬ ជ្រើសរើសតាមប្រភេទសមស្របតាមខ្លឹមសារដែលបានចែងក្នុងផ្នែកនោះ ។

ផ្នែក ២.០៥ : អ្នកខ្ចី ត្រូវទូទាត់សងទៅសមាគម នូវបន្ទុកសេវាមួយតាមអត្រា ៣ ភាគ ៤ នៃ ១% ក្នុងមួយឆ្នាំលើចំនួនប្រាក់ដើម នៃឥណទានដែលបានដក និងចំនួនកំពុងប្រព្រឹត្តទៅបន្តបន្ទាប់ ។

ផ្នែក ២.០៦ : បន្ទុកកិច្ចសន្យា និង បន្ទុកសេវា ត្រូវទូទាត់ពីរដងក្នុងមួយឆ្នាំ ពោលគឺនៅថ្ងៃទី ០១ ខែ ឧសភា ម្តង និងនៅថ្ងៃទី ០១ ខែ វិច្ឆិកា ម្តងរៀងរាល់ឆ្នាំ ។

ផ្នែក ២.០៧ : យោងតាមកថាខ័ណ្ឌ «ខ» និង «គ» ខាងក្រោម អ្នកខ្ចីត្រូវទូទាត់សងវិញចំពោះប្រាក់ដើម នៃឥណទានពីរដងក្នុងមួយឆ្នាំ នៅថ្ងៃទី ០១ ឧសភា ម្តងនិង ថ្ងៃទី ០១ វិច្ឆិកា ម្តងជារៀងរាល់ឆ្នាំ ដោយចាប់ផ្តើមពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៥ ព្រមទាំងបញ្ចប់នៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០៣៤ ។ ការទូទាត់ តាមលើកនីមួយៗ រួមទាំងចាប់ពីដើមដំបូង ពោលគឺថ្ងៃទី ០១ ឧសភា ឆ្នាំ ២០១៤ ត្រូវជា ១ ភាគរយ លើចំនួនប្រាក់ដើម ។ ហើយក្រោយមកការទូទាត់តាមលើកនីមួយៗ ត្រូវកំណត់ ២ ភាគរយ លើចំនួនប្រាក់ដើម ។

(ខ): ពេលណា (i) ផលិតផលជាតិដុលក្នុងម្នាក់ៗ ដែលកំណត់ដោយសមាគមលើសពីប្រាំពីររយកៅសិប «៧៩០» ដុល្លារអាមេរិក គិតតាមតំលៃស្មើរ ភាពនាឆ្នាំ ១៩៨៥ សំរាប់ ៥ ឆ្នាំ បន្តបន្ទាប់ ហើយ (ii) ធនាគារចាត់ទុកអ្នកខ្ចី «អ្នកមានលទ្ធភាពសង» សមាគមអាចកែសំរួលលើប្រការទូទាត់តាមដំណាក់ៗ ក្រោមកថាខ័ណ្ឌខាងលើ តំរូវអោយអ្នកខ្ចីទូទាត់ជាពីរដងលើចំនួនដែលត្រូវទូទាត់តាមលើកនីមួយៗ រហូតដល់ឥណទានទាំងមូលត្រូវទូទាត់រួចរាល់ ។ បើសិនជាមានសំណូមពរពីអ្នកខ្ចី សមាគមអាចពិនិត្យកែសំរួលឡើងវិញ លើករណីខ្លះៗ ឬ ទាំងអស់លើចំនួននៃជំហានទូទាត់បែបនេះ ការសងការតាមអត្រាប្រចាំឆ្នាំ បានឯកភាពជាមួយសមាគមលើចំនួនប្រាក់ដើម នៃឥណទានដែលបានដក និង ចំនួនកំពុងប្រព្រឹត្តទៅ

ជាបន្តបន្ទាប់ ។ ក្នុងការវិនិច្ឆ័យ របស់សមាគម ការពិនិត្យឡើងវិញ នឹងមិនផ្លាស់ប្តូរកត្តាសំខាន់ៗ ដែលទទួលបានក្រោមការកែសម្រួលទូទាត់ តួសបញ្ជាក់ខាងលើ ។

(គ): បើសិនជានៅពេលណាមួយ បន្ទាប់ពីមានការកែសម្រួលលើលក្ខខ័ណ្ឌតាមកថាខ័ណ្ឌ «ខ» ខាងលើ និង ក្រោយពេលក្រុមប្រឹក្សាភិបាលធនាគារបានពិចារណា ហើយសមាគមកំណត់ថា បើលក្ខខ័ណ្ឌសេដ្ឋកិច្ចរបស់អ្នកខ្ចីធ្លាក់យ៉ាងខ្លាំងនោះ យោងតាមសំណើរបស់អ្នកខ្ចី ធនាគារអាចកែលំអលក្ខខ័ណ្ឌដើម ក្នុងការសងអនុលោមតាមកម្មវិធីទូទាត់តាមលើកនីមួយៗ នៃកថាខ័ណ្ឌ (ខ) ខាងលើ ។

ផ្នែក ២.០៥ : រូបិយវត្ថុ នៃសហរដ្ឋអាមេរិក គឺត្រូវបានបញ្ជាក់ សំរាប់គោលបំណងនានានៃផ្នែក៤.០២ នៃលក្ខខ័ណ្ឌទូទៅ ។

មាត្រា III
ប្រតិបត្តិគំរោង

ផ្នែក ៣.០១ (ក) : អ្នកខ្ចីប្រកាសនូវកិច្ចសន្យារបស់ខ្លួន ចំពោះគោលដៅ នៃគំរោងនេះ ឆ្លងតាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ភ្នាក់ងារអនុវត្តគំរោងជាមួយនឹងការយកចិត្តទុកដាក់ ផ្តល់ផលប្រយោជន៍រៀបចំ សមស្របលើការងាររដ្ឋបាលសេដ្ឋកិច្ច ហិរញ្ញវត្ថុ បច្ចេកទេស សំភារៈ សេវាសាធារណៈ ដើម្បីឆ្លើយតបបានទាន់ពេលវេលា ។

(ខ) : អ្នកខ្ចី ត្រូវអនុវត្តសមស្របតាមផែនការអនុវត្តគំរោង ដូចបានចែងក្នុងកម្មវិធី ៥ នៃកិច្ចព្រមព្រៀងដោយគ្មានកំណត់ព្រំដែន អនុលោមតាមកថាខ័ណ្ឌ «ក» នៃផ្នែកនេះ លើកលែងតែមានការព្រមព្រៀងរវាងអ្នកខ្ចី និងសមាគម។

ផ្នែក ៣.០២ : អនុលោមតាមសេចក្តីដែលបានចែងក្នុងមាត្រា ៩ នៃលក្ខខ័ណ្ឌទូទៅ អ្នកខ្ចីត្រូវ :

(ក): រៀបចំ និង ផ្គត់ផ្គង់ដល់សមាគមអោយបានមុន ៦ ខែបន្ទាប់ពីកាលបរិច្ឆេទបន្ទាប់ណាមួយទៀតដែលបានឯកភាពគ្នារវាងអ្នកខ្ចី និង សមាគមនូវផែនការចំណុចដៅជាលំអិតតាមសំណើ សមហេតុផលរបស់សមាគម សំរាប់កិច្ច

ង–«គអក» មានន័យថា គណៈកម្មាធិការបច្ចេកទេសអន្តរក្រសួងផ្នែកកែទំរង់រដ្ឋបាល បង្កើតឡើងយោងតាមអនុក្រឹត្យលេខ ២៣ ចុះថ្ងៃទី ០៩ ឧសភា ឆ្នាំ ១៩៩៤

ច–«អកច» មានន័យថា អង្គភាពកែទំរង់ច្បាប់ត្រូវបានបង្កើតឡើងដោយអ្នកខ្ចីក្នុងក្របខ័ណ្ឌក្រុមប្រឹក្សាអ្នកច្បាប់យោងតាមប្រការដែលបានចែងក្នុងផ្នែក ៣.០៥ «ក» នៃកិច្ចព្រមព្រៀងនេះ

ឆ–«សហវ» មានន័យថា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់អ្នកខ្ចី

ជ–«ពណ» មានន័យថា ក្រសួងពាណិជ្ជកម្មរបស់អ្នកខ្ចី

ឈ–«យធ» មានន័យថា ក្រសួងយុត្តិធម៌របស់អ្នកខ្ចី

ញ–«ធជក» មានន័យថា ធនាគារជាតិ នៃកម្ពុជារបស់អ្នកខ្ចី

ដ–«អគក» មានន័យថា អង្គភាពគ្រប់គ្រងគំរោង បង្កើតឡើងដោយអ្នកខ្ចី ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អនុលោមតាមប្រកាសលេខ ២៨៩ ប្រក ចុះថ្ងៃទី ២៨ វិច្ឆិកា ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឋ–«ភ្នាក់ងារគំរោង» មានន័យថា ក្រសួងស្ថាប័ន និង ភ្នាក់ងារនានារបស់អ្នកខ្ចីដែលមានភារកិច្ចជួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងការអនុវត្តន៍គំរោង ។ ភ្នាក់ងារគំរោងទាំងនេះត្រូវផ្អែកតាមឧបសម្ព័ន្ធក្នុងកម្មវិធី ២ របស់កិច្ចព្រមព្រៀងនេះ ។

ឌ–ផែនការអនុវត្តន៍គំរោងមានន័យថា ផែនការសំរាប់អនុវត្តគំរោងរបស់អ្នកខ្ចី ហើយត្រូវបានផ្អែកតាមក្នុងផ្នែក ៣.០១ (២) និង មានចែងក្នុងកម្មវិធី ៥ ក្នុងកិច្ចព្រមព្រៀង ។

ឍ–«គណនីពិសេស» មានន័យថា ជាគណនីដែលបានចែងក្នុងផ្នែក ២.០២ (២) របស់កិច្ចព្រមព្រៀង ។

មាត្រា II

ឥណទាន

ផ្នែក ២.០១ : សមាគមឯកភាពផ្តល់អោយអ្នកខ្ចី លើលក្ខខ័ណ្ឌ និង ប្រការនានាដែលបានចែង ឬ តាមកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍នេះ ស្មើចំនួនទឹកប្រាក់មួយជារូបិយវត្ថុផ្សេងៗគ្នាសមមូលនឹងចំនួន ដប់មួយលានប្រាំមួយរយពាន់

SDR «១១,៦០០,០០០ » ។

ផ្នែក ២.០២(ក) : ចំនួនទឹកប្រាក់នៃឥណទាន ដែលអាចដកគណនីឥណទាន អនុលោមតាមប្រការទាំងឡាយ ដែលបានចែងក្នុងកិច្ចព្រមព្រៀងឥណទាន សំរាប់យកមកចំណាយ ឬ ត្រូវបានចំណាយក្រោយពីបានឯកភាពពីសមាគមត្រូវគោរពតាម តំលៃសមហេតុផល របស់ទំនិញ សេវា ដែលត្រូវការរបស់គំរោងដូចបានចែងក្នុងកម្មវិធី ២ នៃកិច្ចព្រមព្រៀងព្រមទាំងត្រូវបានផ្តល់ហិរញ្ញប្បទានចេញពីចំនួនទឹកប្រាក់ នៃឥណទាន ។

(ខ) :ដើម្បីគោលដៅនៃគំរោង អ្នកខ្ចីត្រូវបើកគណនីពិសេសមួយ ជាដុល្លារអាមេរិកនៅធនាគារជាតិនៃកម្ពុជា លើលក្ខខ័ណ្ឌដ៏ប្រសើររបស់សមាគមដោយប្រព្រឹត្តទៅសមស្របរួមការពារទប់ទល់ការប៉ះប៉ូវីបអូស ។ ប្រាក់តំកល់ និងការទូទាត់តាមរយៈគណនីពិសេសនេះនឹងប្រព្រឹត្តទៅត្រឹមត្រូវតាមខ្លឹមសារដែលបានចែងក្នុងកម្មវិធី ៤ នៃកិច្ចព្រមព្រៀងនេះ ។

ផ្នែក ២.០៣ : កាលបរិច្ឆេទបញ្ចប់ឥណទានត្រូវបានគ្រោង នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០១ ឬ អាចក្រោយកាលបរិច្ឆេទនេះ យោលទៅលើសមាគម ។ សមាគមនឹងជូនដំណឹងស្តីពី កាលបរិច្ឆេទថ្មីដល់អ្នកខ្ចីអោយបានឆាប់រហ័ស ។

ផ្នែក ២.០៤(ក) : អ្នកខ្ចីត្រូវបង់ជូនសមាគម នូវបន្ទុកកិច្ចសន្យាតាមអត្រាមួយដែលកំណត់ដោយសមាគមលើចំនួនទឹកប្រាក់នៃឥណទានដែលមិនទាន់ បានដកប្រើ នៅថ្ងៃទី ៣០ ខែ មិថុនា រៀងរាល់ឆ្នាំ ក៏ប៉ុន្តែអត្រានោះមិនអោយលើសពីពាក់កណ្តាល នៃមួយភាគរយក្នុងមួយឆ្នាំ ។

(ខ) : បន្ទុកកិច្ចសន្យាចាប់គិតពី ៦០ ថ្ងៃ (i) បន្ទាប់ពីកិច្ចព្រមព្រៀងចូលជាធរមានទៅទល់នឹងកាលកំណត់មួយដែលចំនួននោះ ត្រូវបានដកដោយអ្នកខ្ចីពីគណនីឥណទាន ឬត្រូវបានលុបចោល ។ (ii) និង តាមអត្រាកំណត់ក្នុងថ្ងៃទី ៣០ មិថុនា ក្រោយពេលកិច្ចព្រមព្រៀងចូលជាធរមានភ្លាមៗ ឬ តាមអត្រាផ្សេងទៀតជាបន្តបន្ទាប់ យោងតាមកថាខ័ណ្ឌ ក ខាងលើ ។ អត្រាដែលកំណត់ នៅថ្ងៃទី ៣០ មិថុនា នៃឆ្នាំនីមួយៗ ត្រូវបានចាប់អនុវត្តពីកាលបរិច្ឆេទទូទាត់បន្ទាប់នៃឆ្នាំនោះ ដូចដែលបានបញ្ជាក់ក្នុងផ្នែក ២.០៦ នៃកិច្ចព្រមព្រៀងនេះ។

(គ): អ្នកខ្ចីត្រូវទូទាត់សងបន្ទុកកិច្ចសន្យា (i) តាមទីកន្លែងដែលសមាគម

សំណូមពរ (ii) ដោយគ្មានព្រំដែនលើប្រភេទចាប់បង្ខំណាមួយ (iii) ហើយដោយរូបិយប័ណ្ណជាក់លាក់ក្នុងកិច្ចព្រមព្រៀងនេះ ដើម្បីគោលបំណងក្នុងផ្នែក ២.០៤ នៃលក្ខខ័ណ្ឌទូទៅទាំងឡាយ ឬ រូបិយប័ណ្ណផ្សេងទៀតដែលយកជាការបាន ឬ ជ្រើសរើសតាមប្រភេទសមស្របតាមខ្លឹមសារដែលបានចែងក្នុងផ្នែកនោះ ។

ផ្នែក ២.០៥ : អ្នកខ្ចី ត្រូវទូទាត់សងទៅសមាគម នូវបន្ទុកសេវាមួយតាមអត្រា ៣ ភាគ ៤ នៃ ១% ក្នុងមួយឆ្នាំលើចំនួនប្រាក់ដើម នៃឥណទានដែលបានដក និង ចំនួនកំពុងប្រព្រឹត្តទៅបន្តបន្ទាប់ ។

ផ្នែក ២.០៦ : បន្ទុកកិច្ចសន្យា និង បន្ទុកសេវា ត្រូវទូទាត់ពីរដងក្នុងមួយឆ្នាំ ពោលគឺនៅថ្ងៃទី ០១ ខែ ឧសភា ម្តង និងនៅថ្ងៃទី ០១ ខែ វិច្ឆិកា ម្តងរៀងរាល់ឆ្នាំ ។

ផ្នែក ២.០៧ : យោងតាមកថាខ័ណ្ឌ «ខ» និង «គ» ខាងក្រោម អ្នកខ្ចីត្រូវទូទាត់សងវិញចំពោះប្រាក់ដើម នៃឥណទានពីរដងក្នុងមួយឆ្នាំ នៅថ្ងៃទី ០១ ឧសភាម្តងនិង ថ្ងៃទី ០១ វិច្ឆិកា ម្តងជារៀងរាល់ឆ្នាំ ដោយចាប់ផ្តើមពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៥ ព្រមទាំងបញ្ចប់នៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០៣៤ ។ ការទូទាត់ តាមលើកនីមួយៗ រួមទាំងចាប់ពីដើមដំបូង ពោលគឺថ្ងៃទី ០១ ឧសភា ឆ្នាំ ២០១៤ ត្រូវជា ១ ភាគរយ លើចំនួនប្រាក់ដើម ។ ហើយក្រោយមកការទូទាត់តាមលើកនីមួយៗ ត្រូវកំណត់ ២ ភាគរយ លើចំនួនប្រាក់ដើម ។

(ខ): ពេលណា (i) ផលិតផលជាតិដុលក្នុងម្នាក់ៗ ដែលកំណត់ដោយសមាគមលើសពីប្រាំពីររយកៅសិប «៧៩០» ដុល្លារអាមេរិក គិតតាមតំលៃស្មើរ ភាពនាឆ្នាំ ១៩៨៥ សំរាប់ ៥ ឆ្នាំ បន្តបន្ទាប់ ហើយ (ii) ធនាគារចាត់ទុកអ្នកខ្ចី «អ្នកមានលទ្ធភាពសង» សមាគមអាចកែសំរួលលើប្រការទូទាត់តាមដំណាក់ៗ ក្រោមកថាខ័ណ្ឌខាងលើ តំរូវអោយអ្នកខ្ចីទូទាត់ជាពីរដងលើចំនួនដែលត្រូវទូទាត់តាមលើកនីមួយៗ រហូតដល់ឥណទានទាំងមូលត្រូវទូទាត់រួចរាល់ ។ បើសិនជាមានសំណូមពរពីអ្នកខ្ចី សមាគមអាចពិនិត្យកែសំរួលឡើងវិញ លើករណីខ្លះៗ ឬ ទាំងអស់លើចំនួន/នៃជំហានទូទាត់បែបនេះ ការសងការតាមអត្រាប្រចាំឆ្នាំ បានឯកភាពជាមួយសមាគមលើចំនួនប្រាក់ដើម នៃឥណទាន ដែលបានដក និង ចំនួនកំពុងប្រព្រឹត្តទៅ

ជាបន្តបន្ទាប់ ។ ក្នុងការវិនិច្ឆ័យ របស់សមាគម ការពិនិត្យឡើងវិញ នឹងមិនផ្លាស់ប្តូរកត្តាសំខាន់ៗ ដែលទទួលបានក្រោមការកែសម្រួលទូទាត់ គួសបញ្ជាក់ខាងលើ ។

(គ): បើសិនជានៅពេលណាមួយ បន្ទាប់ពីមានការកែសម្រួលលើលក្ខខ័ណ្ឌតាម កថាខ័ណ្ឌ «ខ» ខាងលើ និង ក្រោយពេលក្រុមប្រឹក្សាភិបាលធនាគារបាន ពិចារណា ហើយសមាគមកំណត់ថា បើលក្ខខ័ណ្ឌសេដ្ឋកិច្ចរបស់អ្នកខ្ចីធ្លាក់ យ៉ាងខ្លាំងនោះ យោងតាមសំណើរបស់អ្នកខ្ចី ធនាគារអាចកែលំអលក្ខខ័ណ្ឌ ដើម ក្នុងការសងអនុលោមតាមកម្មវិធីទូទាត់តាមលើកនីមួយៗ នៃកថាខ័ណ្ឌ (គ) ខាងលើ ។

ផ្នែក ២.០៨ : រូបិយវត្ថុ នៃសហរដ្ឋអាមេរិក គឺត្រូវបានបញ្ជាក់ សំរាប់គោលបំណងនានានៃ ផ្នែក៤.០២ នៃលក្ខខ័ណ្ឌទូទៅ ។

មាត្រា III

ប្រតិបត្តិគំរោង

ផ្នែក ៣.០១ (ក): អ្នកខ្ចីប្រកាសនូវកិច្ចសន្យារបស់ខ្លួន ចំពោះគោលដៅ នៃគំរោងនេះ ឆ្លងតាម ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ភ្នាក់ងារអនុវត្តគំរោងជាមួយនឹងការ យកចិត្តទុកដាក់ ផ្តល់ផលប្រយោជន៍រៀបចំ សមស្របលើការងាររដ្ឋបាល សេដ្ឋកិច្ច ហិរញ្ញវត្ថុ បច្ចេកទេស សំភារៈ សេវាសាធារណៈ ដើម្បីឆ្លើយតប បានទាន់ពេលវេលា ។

(ខ): អ្នកខ្ចី ត្រូវអនុវត្តសមស្របតាមផែនការអនុវត្តគំរោង ដូចបានចែងក្នុងកម្ម វិធី ៥ នៃកិច្ចព្រមព្រៀងដោយគ្មានកំណត់ព្រំដែន អនុលោមតាមកថាខ័ណ្ឌ «ក» នៃផ្នែកនេះ លើកលែងតែមានការព្រមព្រៀងរវាងអ្នកខ្ចី និងសមាគម។

ផ្នែក ៣.០២ : អនុលោមតាមសេចក្តីដែលបានចែងក្នុងមាត្រា ៩ នៃលក្ខខ័ណ្ឌទូទៅ អ្នកខ្ចី ត្រូវ :

(ក): រៀបចំ និង ផ្តត់ផ្គង់ដល់សមាគមអោយបានមុន ៦ ខែបន្ទាប់ពីកាលបរិច្ឆេទ បន្ទាប់ណាមួយទៀតដែលបានឯកភាពគ្នារវាងអ្នកខ្ចី និង សមាគមនូវផែន ការចំណុចដៅជាលំអិតតាមសំណើ សមហេតុផលរបស់សមាគម សំរាប់កិច្ច

ប្រតិបត្តិគំរោងទៅអនាគត ។

(ខ):បង្កលក្ខណៈដល់សមាគមនូវឱកាសសមស្របមួយក្នុងការប្តូរទស្សនៈជាមួយអ្នកខ្ចី លើផែនការខាងលើ

(គ):អនុវត្តផែនការដោយត្រឹមត្រូវ និងមានប្រសិទ្ធភាពយោលទៅតាមបទពិសោធន៍ជាក់ស្តែង និង ស្របតាមគោលបំណងរបស់ធនាគារ

ផ្នែក៣.០៣(ក): ជានិច្ចជាកាល រហូតដល់ចុងបញ្ចប់នៃគំរោង អ្នកខ្ចីត្រូវរក្សា អគគ ក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងកំលាំងមនុស្ស និង សំភារៈចាំបាច់ ធ្វើអោយប្រាកដថា អគគ ត្រូវបានដឹកនាំដោយអ្នកសំរបសំរួលគំរោង ដោយមានសមត្ថភាព និង ទទួលយកបានដោយសមាគម ហើយមន្ត្រីដែលបំរើការងារទៀតសោត ត្រូវមានសមត្ថភាពជាមួយបរិមាណសមរម្យហើយផ្តល់បានជាប់រហ័ស នូវរាល់មូលនិធិគ្រឿងសំភារៈ សេវាផ្សេងៗទៀត ដែលតំរូវការដើម្បីអោយ អគគ បំពេញភារកិច្ចមុខងារ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

(ខ): អគគ ជាបឋមត្រូវតែយកចិត្តទុកដាក់ធ្ងន់លើការងារគ្រប់គ្រងជាទូទៅ រដ្ឋបាល កិច្ចសំរបសំរួលអនុវត្តគំរោងរួមទាំងការផ្គត់ផ្គង់រាល់ទំនិញសេវាកម្មការងារ ។ល។ តាមសំណូមពរ ។

(គ): អ្នកខ្ចីត្រូវបង្កលក្ខណៈដល់ អគគ ក្នុងការរៀបចំ និង ផ្គត់ផ្គង់ដល់សមាគមលើការសើរើពិនិត្យអោយបានមុនថ្ងៃទី ៣០ មិថុនា និង ៣១ ធ្នូ ក្នុងឆ្នាំសារពើពន្ធនីមួយៗ លើរបាយការណ៍ប្រចាំឆ្នាំ ស្តីពីដំណើរការអនុវត្តន៍គំរោងរបស់អ្នកខ្ចី ព្រមទាំងរាល់ការចំណាយទាក់ទងទៅនឹងគំរោងនេះ ។

ផ្នែក ៣.០៤ : សំរាប់គោលបំណងនៃការអនុវត្តន៍គ្រង់ភាគ ក.១ នៃគំរោង អ្នកខ្ចីត្រូវ :

(ក): តែងតាំងមន្ត្រីទាំងឡាយដែលត្រូវរួមសហការ លើលក្ខខ័ណ្ឌទាំងឡាយដែលព្រមព្រៀងគ្នា ដោយពេញចិត្តរបស់សមាគម ក្នុងកិច្ចសហការ នៅពេលអ្នកជំនួយការមកដល់ ឬការប្រគល់នូវប្រព័ន្ធគ្រប់គ្រងពត៌មានវិទ្យា និងធ្វើអោយប្រាកដថា ភ្នាក់ងារគំរោងដែលអនុវត្តនូវមុខសញ្ញាផែនការការងារខ្លួនតំយោង លើកម្មវិធី ការងារឆ្នាំ នៃផែនការក្រោមផែនការអនុវត្តន៍គំរោង និងបន្ទាប់មកទៀតត្រូវសើរើពិនិត្យ និង តាមដានជាប់លើផែនការនេះ ដោយពិគ្រោះយោបល់ជាមួយសមាគម អោយបានមុនថ្ងៃទី ៣១ មិថុនា

រៀងរាល់ឆ្នាំសារពើពន្ធ ដោយចាប់ផ្ដើមពីពេលបញ្ចប់ឆ្នាំសារពើពន្ធនាថ្ងៃទី ៣១ ធ្នូ ឆ្នាំ ១៩៩៥ ។

ផ្នែក ៣.០៥ : សំរាប់គោលបំណងនៃការអនុវត្តចំនែកភាគ ខ នៃគំរោងអ្នកខ្ចីត្រូវ :(ក) បង្កើត និង រក្សារហូតដល់ពេលបញ្ចប់ នៃគំរោងនូវអង្គភាពកែទម្រង់ច្បាប់ (អកច ក្រោមនិរាទ កច) អោយបានមុនថ្ងៃទី ៣០ មិថុនា ឆ្នាំ ១៩៩៥ ។ ការបង្កើតអង្គភាពនេះ ត្រូវសមស្របទៅនឹងប្រការទាំងឡាយ និង ប្រភពធនធានដែលសមាគមពេញចិត្ត ត្រូវបានដឹកនាំជាប្រចាំដោយទីប្រឹក្សាអ្នកច្បាប់ ដែលពោរពេញទៅដោយបទពិសោធន៍ និង បានទទួលជំនួយគាំទ្រយ៉ាងមុតមាំពីមន្ត្រីស្អាតជំនាញខាងច្បាប់មួយចំនួនសមស្រប (ខ) រៀបចំអនុម័តរបាយការណ៍ជាផ្លូវការស្ដីពីច្បាប់សេដ្ឋកិច្ច និង ហិរញ្ញវត្ថុព្រមទាំងបទបញ្ញាផ្សេងៗ ដែលត្រូវផ្សព្វផ្សាយក្នុងកំឡុងពេលពីឆ្នាំ ១៩៩៥ ដល់ ១៩៩៨ សំរាប់អភិវឌ្ឍន៍នូវ មូលដ្ឋានសេដ្ឋកិច្ចទីផ្សារ សកម្មភាពវិស័យឯកជន ។

ផ្នែក ៣.០៦ :ដោយគោរពទៅតាមកម្មវិធីសិក្សា បំពាក់បំប៉នដែលត្រូវអនុវត្តក្រោម ភាគ គ នៃគំរោង អ្នកខ្ចីត្រូវផ្ដល់ដល់សមាគម ក្នុងការអនុមតិមុនគេ :(ក)ប្រការជាមូលដ្ឋានទាំងឡាយក្នុងការអនុវត្តន៍ផ្ដល់ហិរញ្ញប្បទាន និង ត្រួតពិនិត្យតាមដាន ការសិក្សាខាងលើ និង (ខ) ប្រការជាមូលដ្ឋាន នៃកម្មវិធីបណ្ដុះបណ្ដាល ទាំងឡាយព្រមទាំងកម្មវិធីសំរាប់ការអនុវត្តន៍របស់វា និង លក្ខណៈសម្បត្តិជ្រើសរើសមុខសញ្ញាអោយចូលក្នុងវគ្គបណ្ដុះបណ្ដាលនេះ ។

ផ្នែក ៣.០៧ : គ្មានកំណត់ព្រំដែន អនុលោមតាមខ្លឹមសារទាំងឡាយ ដែលបានចែងក្នុងលក្ខខ័ណ្ឌទូទៅ នៃកិច្ចព្រមព្រៀង :(ក) លើមូលដ្ឋាននៃប្រការទាំងឡាយដែលសមាគមទទួលយល់ព្រម អោយបានមុនថ្ងៃទី ៣០ មិថុនា ១៩៩៧ អ្នកខ្ចីត្រូវដឹកនាំវគ្គយល់ដឹងស្ដីពីការសើរើពិនិត្យឡើងវិញ លើលទ្ធផលនៃការអនុវត្តន៍គំរោងរបស់អ្នកខ្ចី និង (ខ) ចាប់អារម្មណ៍ដល់យោបល់ណែនាំរបស់សមាគម ក្រោយពីការសើរើពិនិត្យអ្នកខ្ចីត្រូវតែអនុវត្តអោយបានត្រឹមត្រូវ និង ប្រកបដោយប្រសិទ្ធភាព ព្រមទាំងចាត់រាល់វិធានការចាំបាច់ដើម្បីឈានទៅសំរេច អោយបានជោគជ័យទាំងស្រុង ចំពោះគោលដៅនៃគំរោង ។

ផ្នែក ៣.០៨ : លើកលែងតែមានការព្រមព្រៀងដោយឡែកពីសមាគម ការផ្គត់ផ្គង់ទំនិញ ការ ងារសេវាសំរាប់គំរោង ហើយត្រូវបានផ្តល់ហិរញ្ញប្បទានចេញឥណទាន ត្រូវគោរពតាមខ្លឹមសារនៃឧបសម្ព័ន្ធដែលបានចែងក្នុងកម្មវិធី ៣ នៃកិច្ចព្រមព្រៀង។

មាត្រា IV

បទបញ្ញត្តិហិរញ្ញវត្ថុ

ផ្នែក ៤.០១ (ក): អ្នកខ្ចីត្រូវរក្សា ឬ បង្កលក្ខណៈអោយមានស្មេរភាព បញ្ជីការអោយបានច្បាស់លាស់ និង ឆ្លុះបញ្ចាំងអោយបានត្រឹមត្រូវ ជាមួយប្រតិបត្តិការជាក់ស្តែងទាំងចំណាយ និង ចំណូល ដោយគោរពតាមគំរោងរបស់នាយកដ្ឋាន ភ្នាក់ងារដែលទទួលខុសត្រូវក្នុងការអនុវត្តន៍គំរោង ឬ ផ្នែកណាមួយ នៃគំរោង

(ខ): អ្នកខ្ចីត្រូវ (i) កត់ត្រា និង បញ្ជីការផ្នែក តាមកថាខ័ណ្ឌ «ក» នៃផ្នែកនេះ ក្នុងនោះក៏ត្រូវធ្វើដូចគ្នាដែរ ចំពោះគណនីពិសេសក្នុងឆ្នាំសារពើពន្ធនីមួយៗ យោលទៅតាមគោលការណ៍ជំរះបញ្ជីសមស្រប ធ្វើឡើងដោយក្រុមជំរះបញ្ជីដែលមានការយល់ព្រមដោយសមាគមផង ។ (ii) ផ្តល់អោយសមាគមអោយបានឆាប់រហ័ស ធ្វើយ៉ាងណាកុំអោយលើសពី ៦ ខែ បន្ទាប់ពីបញ្ចប់ឆ្នាំនីមួយៗ នូវឯកសារមញ្ញាករបាយការណ៍ របស់អ្នកជំរះបញ្ជី ត្រូវលំអិតតាមសំណូមពរសមហេតុផលរបស់សមាគម ។

(iii) ផ្តល់ដល់សមាគមនូវពត៌មានទាក់ទងទៅនឹងកិច្ចបញ្ជីការ និង ការជំរះបញ្ជីគណនីនានាតាមសំណើរបស់សមាគម ។

(គ): ចំពោះរាល់ការចំណាយដែលដកពីគណនីឥណទានគឺត្រូវបានធ្វើលើមូលដ្ឋាននៃសេចក្តីប្រកាស អ្នកខ្ចីត្រូវ : (i) រក្សាបង្កលក្ខណៈ រក្សាស្មេរភាពអនុលោមតាមកថាខ័ណ្ឌ «ក» នៃផ្នែកនេះ ដើម្បីកត់ត្រា និង ឆ្លុះបញ្ចាំងរាល់ការចំណាយបែបនេះ ។ (ii) រក្សាទុកបន្តរហូតដល់យ៉ាងហោចណាស់មួយឆ្នាំសារពើពន្ធពីការដកប្រាក់លើកមុនពីគណនីឥណទាន ឬ ការទូទាត់ ត្រូវបានធ្វើអោយ អស់ពីគណនីពិសេស ការកត់ត្រាទាំងអស់នូវកិច្ចសន្យាបញ្ជាទិញ វិក័យប័ត្រ បង្កាន់ដៃ និង ឯកសារដទៃទៀត ជាសក្ខីប័ត្រចំណាយ ។ (iii)

ជួយធ្វើជា តំណាងអោយសមាគម ដើម្បីត្រួតពិនិត្យលើការកត់ត្រាទាំងអស់នេះ ។ (iv) ធានាការកត់ត្រាគណនីទាំងនេះ ត្រូវបញ្ចូលទាំងការជំរះបញ្ជីក្នុងឆ្នាំ អនុលោមតាមកថាខ័ណ្ឌ «ខ» នៃផ្នែកនេះ ព្រមទាំងរបាយការណ៍នៃការជំរះបញ្ជីនេះ ត្រូវរៀបរាប់កញែកយោបល់របស់អ្នកជំរះបញ្ជីខាង លើ ចំណែកឯរបាយការណ៍ ចំណាយដែលដាក់ជូនក្នុងកំឡុងឆ្នាំសារពើពន្ធរួមជាមួយនឹងទំរង់ការ និង ការត្រួតពិនិត្យផ្ទៃក្នុងទាក់ទង និងការរៀបចំរបស់ខ្លួនអាចទុកចិត្តនិងគាំទ្រដល់ការដកប្រាក់ចេញ ។

មាត្រា V

កាលបរិច្ឆេទជាធរមាន និង កាលកំណត់បញ្ចប់

ផ្នែក ៥.០១ : រយៈពេល ១២០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងត្រូវបានបញ្ជាក់ច្បាស់លាស់ចំពោះគោលដៅ នៃផ្នែក ១២.០៤ នៃលក្ខខ័ណ្ឌទូទៅ ។

ផ្នែក ៥.០២ : កាតព្វកិច្ចរបស់អ្នកខ្ចី ផ្នែកតាមមាត្រា ៣ និង ៤ នៃកិច្ចព្រមព្រៀងនេះ ត្រូវបញ្ឈប់នៅកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងបានបញ្ចប់ឬមួយនៅកាលបរិច្ឆេទម្ភៃ (២០)ឆ្នាំ ក្រោយកាលបរិច្ឆេទកិច្ចព្រមព្រៀងនេះ ដែលជាកាលកំណត់ឆាប់បំផុត ។

មាត្រា VI

តំណាង អ្នកខ្ចី អាស័យដ្ឋាន

ផ្នែក ៦.០១ : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបានជ្រើសរើសជាតំណាងអ្នកខ្ចី សំរាប់គោលបំណងនៃផ្នែក ១១.០៣ នៃលក្ខខ័ណ្ឌទូទៅ ។

ផ្នែក ៦.០២ : អាស័យដ្ឋានខាងក្រោមត្រូវបានបញ្ជាក់ច្បាស់សំរាប់គោលបំណងផ្នែក ១១.០១ នៃលក្ខខ័ណ្ឌទូទៅ ។

ចំពោះភាគីអ្នកខ្ចី : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

តេឡិច :(៥៨៣)១៧៧០១០១ CMPP

ចំពោះសមាគម : សមាគមអភិវឌ្ឍន៍អន្តរជាតិ

វិថីលេខ : ១៨១៨ H,N.W

វ៉ាស៊ីនតោន, ឌីស៊ី . ២០៤៣៣

សហរដ្ឋអាមេរិក

Telex :

cable Address

INDEVAS ២៤៨៤២៣

(RCA),

វ៉ាស៊ីនតោន, ឌីស៊ី ៨២៩៨៧

(FTCC),

៦៤១៤៥

(WUI)or

១៩៧៦៨៨

(TRT).

ដើម្បីជាសក្ខីភាពភាគីទាំងពីរ ដែលកំពុងអនុវត្តតាមរយៈតំណាងដែលបានទទួលការអនុញ្ញាតសិទ្ធិត្រឹមត្រូវរបស់ភាគីនីមួយៗ បានបង្កលក្ខណៈអោយកិច្ចព្រមព្រៀងឥណទាន បានចុះហត្ថលេខារៀងៗ ខ្លួននៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃ. ខែ. ឆ្នាំ ដែលបានចែងពីដំបូងខាងលើ ។

ព្រះរាជាណាចក្រកម្ពុជា

ដោយ តំណាងមានសមត្ថកិច្ច **គាត ឈន់**

សមាគមអភិវឌ្ឍន៍អន្តរជាតិ

ដោយ តំណាងមានសមត្ថកិច្ច **អាឈរ្វ ហ្គីណា**

* * *

កម្មវិធី១

ការដកប្រាក់ឥណទាន

១–តារាងខាងក្រោមចែងអំពីប្រភេទមុខចំណាយដែលត្រូវបានហិរញ្ញប្បទានពីទឹកប្រាក់នៃឥណទានការផ្តល់ចំនួនប្រាក់ នៃឥណទានសំរាប់ប្រភេទមុខចំណាយនីមួយៗ និង ភាគរយនៃមុខចំណាយ ដែលត្រូវបានហិរញ្ញប្បទានក្នុងប្រភេទនីមួយៗ។

ប្រភេទ	ចំនួនប្រាក់ឥណទានត្រូវផ្តល់ សមមូលជា SDR	ភាគរយនៃចំណាយត្រូវហិរញ្ញប្បទាន
(១) សាងសង់ក្នុងផ្នែក (២) នៃគំរោង	៥២២.០០០	៩០%
(២) ទំនិញ	៨៤៧.០០០	១០០%នៃចំណាយក្រៅប្រទេស ១០០%នៃចំណាយក្នុងស្រុក (បរិយាទានផលិតកម្ម) និង ៩០% ចំណាយក្នុងប្រទេសសំរាប់ទំនិញផ្សេងៗទៀតក្នុងស្រុក។
(៣) សេវាពិគ្រោះ	៧.៩៥៣.០០០	១០០%
(៤) បណ្តុះបណ្តាល	៩៧៨.០០០	១០០%
(៥) ការសិក្សាស្រាវជ្រាវ	៧៨២.០០០	១០០%
(៦) ត្រៀមបំរុង	៥១៨.០០០	

សរុប ១១.៦០០.០០០

២–សំរាប់គោលបំណងនៃកម្មវិធី ១ :

ពាក្យ «ចំណាយក្រៅប្រទេស» មានន័យថាចំណាយជារូបិយវត្ថុរបស់ប្រទេសណាមួយក្រៅពីប្រទេសអ្នកខ្ចីសំរាប់ទិញ ឬសេវាដែលផ្គត់ផ្គង់ពីទឹកដីនៃប្រទេសក្រៅក្រៅពីប្រទេស អ្នកខ្ចី និង

ពាក្យ «ចំណាយក្នុងប្រទេស» មានន័យថា ចំណាយជារូបិយវត្ថុ របស់ប្រទេសអ្នកខ្ចីសំរាប់ទំនិញ ឬ សេវា ដែលផ្គត់ផ្គង់ពីទឹកដីនៃប្រទេសអ្នកខ្ចី ។

៣–ដោយបដិបញ្ញត្តិចំពោះកថាខ័ណ្ឌ ១ ខាងលើការដកប្រាក់សំរាប់ទូទាត់ចំណាយពុំអាចប្រព្រឹត្តទៅបានមុនកាលបរិច្ឆេទ នៃកិច្ចព្រមព្រៀងនេះទេ ។

៤–សមាគមអាចតំរូវអោយដកប្រាក់ពីគណនីឥណទាន ដែលធ្វើឡើងដោយផ្អែកលើមូលដ្ឋានបញ្ជីសំរង់ចំណាយតាមកិច្ចសន្យាទាំងឡាយ :

តំលៃការងារមិនហួសសមមូលមួយរយពាន់ដុល្លារ (១០០.០០០)
ទំនិញមិនហួសសមមូល ហាសិបពាន់ដុល្លារ (៥០.០០០)
ក្រុមហ៊ុនពិគ្រោះមិនហួសសមមូលមួយរយពាន់ដុល្លារ (១០០.០០០)
អ្នកពិគ្រោះជាបុគ្គលមិនហួសសមមូលហាសិបពាន់ដុល្លារ (៥០.០០០) និង
គ្រប់តំលៃបណ្តុះបណ្តាលទាំងអស់ក្រោមកាលកំណត់ និង លក្ខខ័ណ្ឌកាលណាសមាគមបញ្ជាក់សេចក្តី ប្រកាសជូនអ្នកខ្ចី ។

កម្មវិធី២

ពិពណ៌នាអំពីគំរោងការ

គោលដៅនៃគំរោងការ គឺជួយអោយអ្នកខ្ចីបង្កើត និងអនុវត្តការកែទំរង់ស្ថាប័នដើម្បី (i) កែលំអការងារគ្រប់គ្រងហិរញ្ញវត្ថុផ្នែកសាធារណៈ និង (ii) បង្កើតបរិដ្ឋាននីតិសម្បទាមួយ សំរាប់អភិវឌ្ឍន៍ឯកជន ។

គំរោងការរួមមានផ្នែកដូចតទៅ ដែលអាចកែប្រែបាន កាលណាអ្នកខ្ចី និង សមាគមយល់ព្រមជាមួយគ្នាថា នឹងឈានដល់គោលដៅទាំងនោះជាបន្ទាន់ :

ផ្នែក ក: ការងារគ្រប់គ្រងផ្នែកសាធារណៈ

១–ផ្តត់ផ្គង់ជំនួយការបច្ចេកទេស ដើម្បីជួយជ្រោមជ្រែង ដល់អ្នកខ្ចី ក្នុងការអនុវត្តវិធីកែទំរង់ការងារគ្រប់គ្រង ផ្នែកសាធារណៈដោយ:

(ក) ពង្រឹងសមត្ថភាព ស្ថាប័នរបស់អ្នកខ្ចី តាមរយៈការត្រួតពិនិត្យចំណាយសាធារណៈ ដោយពង្រីកសមត្ថភាពចាំបាច់ការវិភាគម៉ាក្រូសេដ្ឋកិច្ច និងរៀបចំថវិកាជាតិ និងខេត្ត–ក្រុងប្រចាំឆ្នាំ (ii) សមាហរណកម្ម នីតិវិធីគ្រប់គ្រងថវិកា ចូលក្នុងវដ្តនៃផែនការកម្មវិធីថវិកា (iii) កែលំអប្រព័ន្ធអនុវត្ត ថវិកា ធ្វើអធិការកិច្ច និង ត្រួតពិនិត្យ (iv) អភិវឌ្ឍន៍ប្រព័ន្ធមួយសំរាប់អធិការកិច្ច ប្រតិបត្តិការរតនាគារ និង រៀបចំបញ្ជីវិភាគប្រចាំខែ (v) បង្កើតប្រព័ន្ធព្យាករណ៍ប្រចាំខែស្តីពីចំណូលចំណាយរតនៈវត្ថុ (vi) បង្កើតចេញវិធានរដ្ឋបាល

និងគណនេយ្យ ព្រមទាំងនីតិវិធីប្រមូលចំណូល និងកិច្ចប្រតិបត្តិការ ចំណាយ(vii) ពង្រីកនីតិក្របខ័ណ្ឌ និង បទបញ្ញាចំពោះគណនេយ្យសាធារណៈ (viii) កែលំអប្រមូលកិច្ចប្រតិបត្តិការគណនេយ្យ នៅកំរិតមួយនៅតាមខេត្ត–ក្រុង និង (ix) បង្កើតប្រព័ន្ធគណនេយ្យមួយ សំរាប់កិច្ចប្រតិបត្តិការរូបិយវត្ថុបរទេស ។

(ខ) ពង្រឹងសមត្ថភាពស្ថាប័ន របស់អ្នកខ្ចីដើម្បីធ្វើផែនការកម្មវិធី និងគ្រប់គ្រងវិនិយោគសាធារណៈដោយ (i) បង្កើតអង្គភាពថវិកា វិនិយោគសាធារណៈ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ii) អភិវឌ្ឍន៍ ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ តាមបែបពតិមានវិទ្យា នៅអង្គភាពដែលបាន និយាយខាងលើនេះ (iii) បង្កើតនីតិវិធី និង បទបញ្ញាសំរាប់គ្រប់គ្រងវិនិយោគសាធារណៈ និងត្រួតពិនិត្យគំរោងការ (iv) បង្កើតសមត្ថភាពជាយុទ្ធសាស្ត្រ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានិង (v) អភិវឌ្ឍន៍ សមត្ថភាពវិភាគម៉ាក្រូសេដ្ឋកិច្ច នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

(គ) ពង្រឹងសមត្ថភាពស្ថាប័នរបស់អ្នកខ្ចី សំរាប់គ្រប់គ្រងបំណុលក្រៅប្រទេសដោយៈ (i) ពង្រឹង នីតិក្របខ័ណ្ឌ និង ភាពចាំបាច់នៃស្ថាប័ន និង សំរបសំរួលអង្គការចាត់តាំង និងនីតិវិធី រាយការណ៍ ចំពោះការងារគ្រប់គ្រងបំណុលក្រៅប្រទេស និងរបបរាយការណ៍ និង (ii) បង្កើតអង្គភាពគ្រប់គ្រងបំណុលសាធារណៈក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

(ឃ) ពង្រឹង សមត្ថភាពស្ថាប័ន អ្នកខ្ចីសំរាប់កែ ទំរង់ផ្នែកគ្រប់គ្រងមុខងារសាធារណៈ ដោយ តាក់តែងយុទ្ធសាស្ត្រត្រៀមបំរុង និង បង្កើតជំរើសដែលទាក់ទងជាមួយដើម្បីរៀបចំឡើងវិញ នូវមុខងារសាធារណៈរបស់អ្នកខ្ចី និង បង្កើនប្រសិទ្ធភាពរបស់វាទាំងនៅក្នុងសហគ្រាសសាធារណៈទៀតផង ។

២–សាងសង់ និងបំពាក់បរិក្ខារមជ្ឈមណ្ឌលបណ្តុះបណ្តាល វិក្រឹតការ និងសុក្រឹតការជំនាញបច្ចេកទេស ចំនួនប្រហែលប្រាំមួយរយអ្នក (៦០០) ក្នុងមួយឆ្នាំខាងការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

៣–ផ្គត់ផ្គង់ ម៉ាស៊ីនកុំព្យូទ័រ និងសេវា យានយន្ត និងបរិក្ខារស្វ័យប្រវត្តិ ចំពោះសំភារៈ និងមូលដ្ឋានប្រមូលទិន្នន័យ សមស្របទៅនឹងសកម្មភាពសំរាប់កឋាខ័ណ្ឌ ១ខាងលើ ។

ផ្នែក ខៈ ជំនួយការ បច្ចេកទេសគតិយុត្តដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន

១–អនុវត្តការសិក្សានីតិព្យាករណ៍ដើម្បីកំណត់ (ក) វិធីសាស្ត្រ និង បទបញ្ញត្តិអភិវឌ្ឍន៍បច្ចុប្បន្ននៃច្បាប់និងបទបញ្ញាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង(ខ)កំរិតសមត្ថភាពនៃច្បាប់ និង បទបញ្ញា

ផ្សេងៗ នៃ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុព្រមទាំងបទបញ្ញាទាំងឡាយដែលកំពុងអនុវត្តជាធរមាន ទៅទឹកដីរបស់អ្នកខ្ចី ។

២–ធ្វើការប៉ាន់ស្មាន តំរូវការបណ្តុះបណ្តាល ពេញលក្ខណៈច្បាប់ ដើម្បីកំណត់អោយបាននូវតំរូវការស្របច្បាប់ ជាអាទិភាពរបស់អ្នកខ្ចីព្រមទាំងធ្វើសំណូមពរកម្មវិធី សមស្របចាំបាច់ដល់តំរូវការទាំងនេះ ។

៣–ផ្អែកតាមការរកឃើញ និងអនុសាស្ត្រនៃការសិក្សាស្រាវជ្រាវ និងប៉ាន់ស្មានទៅក្នុងកថាខ័ណ្ឌ១ និង ២ ដូចបានចែងខាងលើ និងស្ថានភាពផ្លូវការរបស់អ្នកខ្ចីស្តីពីច្បាប់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាទិភាពដោយអនុលោមតាមផ្នែក ៣,០៥ (ខ)នៃកិច្ចព្រមព្រៀងនេះ ត្រូវរៀបចំ និង អនុវត្តកម្មវិធី ផែនការម្ចាស់ការ ដើម្បីព្រាងនិងត្រួតពិនិត្យច្បាប់ និងបទបញ្ញាជាអាទិភាព នៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង(ខ)រៀបចំបើក សិក្ខាសាលាបណ្តុះបណ្តាលលក្ខណៈច្បាប់សំរាប់ ចៅក្រម,យុត្តិវិទូ មន្ត្រីរាជការ ព្រមទាំងវិជ្ជាជីវៈផ្សេងៗ ទៀតរបស់អ្នកខ្ចី។

៤–បង្កើតប្រព័ន្ធស្វ័យប្រវត្តិ ដើម្បីបោះពុម្ពលើមូលដ្ឋានទៀងទាត់ (ក)រាជកិច្ចរបស់អ្នកខ្ចីជាភាសាខ្មែរបារាំង និងអង់គ្លេស (ខ)សេចក្តីសំរេចរបស់តុលាការកំពូលរបស់អ្នកខ្ចី និងសេចក្តីទាំងឡាយស្តីពីលិទ្ធិ និងនីតិសាស្ត្រ និង (គ)សៀវភៅតម្កល់ម៉ាកសញ្ញាដោយ ពណ

៥–ផ្តត់ផ្គង់ម៉ាស៊ីនកុំព្យូទ័រកម្មវិធី បរិក្ខារស្វ័យប្រវត្តិ សំភារៈមូលដ្ឋានប្រមូលទិន្នន័យសមស្របតាមសកម្មភាព កថាខ័ណ្ឌ ១,២,៣ និង ៤ ដូចបានចែងខាងលើ ។

ផ្នែក គៈ ពង្រឹងបណ្តុះបណ្តាលសិក្សាស្រាវជ្រាវ និងស្ថាប័ន

១–អនុវត្តកម្មវិធីបណ្តុះបណ្តាល (ទាំងក្នុងស្រុកនិងក្រៅស្រុក) ការងារប្រតិបត្តិ សមស្របតាមសកម្មភាពដែលបានចែងក្នុងផ្នែក ក និង ខ ខាងលើ ។

២–ផ្តត់ផ្គង់សេវានីតិប្រឹក្សាដល់ កច,គណ, ពណ,យធ និង គអក

៣–អនុវត្ត (i) សិក្សាស្រាវជ្រាវលើកិច្ចអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុ របស់អ្នកខ្ចី និង (ii) សរិតសំរាំងការសិក្សា គោលនយោបាយផ្អែកតាមវិស័យសេដ្ឋកិច្ចរបស់អ្នកខ្ចី ដូចៈ វាក្យខ័ណ្ឌៈ កសិកម្ម ពាណិជ្ជកម្ម អប់រំ ថាមពល បរិដ្ឋាន សុខាភិបាល ឧស្សាហកម្ម ស្ថិតិ និងភាពដែលអាចធ្វើទៅ បានតាមកម្មវិធីអាស្យាណ្ណ នៃការផ្ទេរបេឡាទៅខេត្តក្រុង ។

៤–ផ្តត់ផ្គង់ជំនួយសំភារៈបច្ចេកទេស និងបណ្តុះបណ្តាលដូច អគគ ក្នុងកិច្ចអនុវត្តន៍ការងារគ្រប់គ្រងគំរោងការ សំរបសំរួល អនុវត្ត ត្រួតពិនិត្យ និងការទទួលខុសត្រូវខាងផ្នែកជេញថ្លៃ ។

៥–ផ្គត់ផ្គង់សំភារៈបរិក្ខាររួមមាន ម៉ាស៊ីនកុំព្យូទ័រ សំភារៈការិយាល័យ បណ្តុះបណ្តាលសមស្រប

តាមសកម្មភាពដែលបាន កំណត់នៅកឋាខ័ណ្ឌ ១.២.៣ និង ៤ខាងលើ ។

ឧបសម្ព័ន្ធ នៃកម្មវិធី ២

ភ្នាក់ងារស្ថាប័នរដ្ឋ របស់អ្នកខ្ចី ដែលបានរាយនាមដូចខាងក្រោម ជាអ្នកទទួលខុសត្រូវក្នុងការជួយជ្រោមជ្រែង រួមចំណែកជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងការអនុវត្តន៍គំរោងការ ។

ផ្នែកនៃគំរោងការ	**ស្ថាប័ន / ភ្នាក់ងារ**
ផ្នែក ក(១)(ក)	សហវ
ផ្នែក ក(១)(ខ)	សហវ/កអក
ផ្នែក ក(១)(គ)	សហវ
ផ្នែក គ(១)(ឃ)	គណ / គអក
ផ្នែក ក(២)	សហវ
ផ្នែក ក(៣)	អគគ
ផ្នែក ខ(១)	កអក/កប/ពណ/យធ
ផ្នែក ខ(២)	កអក/កប/គណ/យធ
ផ្នែក ខ(៣)	គណ/កប/យធ
ផ្នែក ខ(៤)	គណ/ពណ/យធ
ផ្នែក ខ(៥)	អគគ
ផ្នែក គ(១)	អគគ
ផ្នែក គ(២)	កប/គណ/ពណ/យធ
ផ្នែក គ(៣)	សហវ
ផ្នែក គ(៤)	អគគ
ផ្នែក គ(៥)	អគគ

កម្មវិធី ៣

កិច្ចការដេញថ្លៃ និងអ្នកពិគ្រោះ

ផ្នែក I: ដេញថ្លៃទំនិញ និងពលកម្ម

ភាគ ក : ដេញថ្លៃតាមការប្រកួតប្រជែងអន្តរជាតិ

១-លើកលែងករណីដែលបានចែងក្នុងភាគ គ ទំនិញទាំងឡាយត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យាត្រឹមត្រូវតាមកម្មវិធីដែលបានចែងនៅក្នុងផ្នែក I និង II នៃការណែនាំដេញថ្លៃ ខ្ចីបុល «របស់ធនាគារអន្តរជាតិដើម្បីនីតិសម្បទា និងអភិវឌ្ឍន៍ » និង ឥណទានរបស់សមាគមអភិវឌ្ឍន៍អន្តរជាតិ (Guidelines for Procurement under IBRD and IDA Credits) ដែលបានបោះផ្សាយ ដោយធនាគារនៅខែ ឧសភា ឆ្នាំ ១៩៩២ «ការណែនាំ » ព្រមទាំងសមស្របតាមនីតិវិធីលំអិតដូចតទៅ :

(ក) កាលណាកិច្ចសន្យាមានការយឺតយ៉ាវ ហួសរយៈពេលសុពលភាព នៃការដេញថ្លៃដែលបានកំណត់ពីដើមទីនោះរយៈពេលនេះអាចត្រូវបានពន្យារម្តងដងសមស្រប និង អនុលោមតាមបទបញ្ញត្តិ កថាខ័ណ្ឌ ២,៥៩ នៃ «ការណែនាំ» នូវចំនួនពេលអប្បបរមាមួយសំរាប់ បំពេញការវាយតំលៃ ប្រកាសយល់ព្រមជាចាំបាច់ ហើយនិងចុះកិច្ចសន្យា ។ រយៈពេលសុពលភាពនៃការដេញថ្លៃ អាចត្រូវបានពន្យារពេលជាលើកទី២ ក្នុងករណីដែលឯកសារដេញថ្លៃ ឬ ការទាមទារពន្យារពេលផ្តល់នូវការកែតំរូវមួយយ៉ាងសមស្រមអំពីថ្លៃផ្គត់ផ្គង់ ឆ្លុះបញ្ចាំង ការប្រែប្រួលនៃបរិយាទានលទ្ធកម្មរបស់កិច្ចសន្យាក្នុងរយៈពេល នៃការពន្យារពេល ។ ការបង្កើនថ្លៃផ្គត់ផ្គង់ ,គត់គ្រាចូលក្នុងគណនីនៅដំណាក់វាយតំលៃឡើយ ។ ចំពោះកិច្ចសន្យានីមួយៗដែលបានឆ្លងយោបល់សមាគមត្រួតពិនិត្យជាមុនសមស្របតាមបញ្ញត្តិ ភាគ ឃ ១ នៃផ្នែកនេះ ការយល់ព្រមជាមុនរបស់សមាគមទាមទារ: (i) ការពន្យារពេល លើកទី១ នៃរយៈពេលសុពលភាពនៃការដេញថ្លៃ បើរយៈពេលពន្យារនេះហួសចំនួន ៦០ ថ្ងៃ និង(ii) ការពន្យាពេលលើកក្រោយនៃរយៈពេលសុពលភាពនៃការដេញថ្លៃ ។

(ខ) ក្នុងការដេញថ្លៃទំនិញទៅតាមភាគ ក នេះអ្នកខ្ចីត្រូវប្រើប្រាស់បញ្ជីគំរូនៃឯកសារដេញថ្លៃដែលប្រកាសអោយប្រើដោយធនាគារ អ្នកខ្ចីអាចប្រើប្រាស់ឯកសារដេញថ្លៃផ្សេងៗ ទៀតដែល អន្តរជាតិ ទទួលស្គាល់ ហើយសមាគមក៏បានយល់ព្រមផងដែរ ។

ភាគ ខ : ចំណូលចិត្តទៅលើផលិតករក្នុងស្រុក

១–ក្នុងការដេញថ្លៃ ទំនិញតាមនីតិវិធីដែលបានអធិប្បាយក្នុងភាគ ក១ ខាងលើ ទំនិញកម្មន្តសាល ក្នុងទឹកដីរបស់អ្នកខ្ចី អាចទទួលយល់ព្រមបាន ក្នុងកំរិតចំណូលចិត្តមួយសមស្របត្រឹមត្រូវតាម បទបញ្ញត្តិកថាខ័ណ្ឌ ២.៥៥ និង ២.៥៦ និងកថាខ័ណ្ឌពី ១ដល់៤ នៃឧបសម្ព័ន្ធ ២នៃ «ការណែនាំ» ។

ភាគ គ: នីតិវិធីដេញថ្លៃផ្សេងៗទៀត

១–ដេញថ្លៃតាមការប្រជែងក្នុងស្រុក :កិច្ចសន្យាសំរាប់ទំនិញ «រួមទាំងយានយន្ត» និងពលកម្ម ដែលមានតំលៃសមមូល តិចជាងពីររយពាន់ដុល្លារ (២០០.០០០) ក៏ប៉ុន្តែច្រើនជាង ហាសិប ពាន់ដុល្លារ (៥០.០០០) ក្នុងកិច្ចសន្យាមួយរហូតអស់ចំនួនទឹកប្រាក់សរុបសមមូលនឹងប្រាំបួន រយពាន់ ដុល្លារ (៩០០.០០០) អាចត្រូវបានផ្គត់ផ្គង់ដោយកិច្ចសន្យាផ្អែកតាមប្រកាសដេញថ្លៃ ប្រជែងគ្នាក្នុង ស្រុកទៅតាមនីតិវិធីសមស្របរបស់សមាគម ។

២–ដេញថ្លៃតាមការពិគ្រោះ : កិច្ចសន្យាទំនិញ «រួមទាំងយានយន្ត» និងពលកម្មដែលមានតំលៃសមមូលស្មើនឹង ឬ តិចជាងហាសិបពាន់ដុល្លារ (៥០.០០០) ក្នុងមួយកិច្ចសន្យារហូតដល់ចំនួនទឹកប្រាក់សរុបសមមូលនឹងប្រាំមួយរយពាន់ដុល្លារ (៦០០.០០០) អាចត្រូវចុះកិច្ចសន្យាផ្អែកតាមការប្រៀបធៀបបញ្ជីថ្លៃយ៉ាងហោចណាស់មកពីអ្នកផ្គត់ផ្គង់បី (៣) ដែលអាចជ្រើសតាំងបានក្រោម «ការណែនាំ» សមស្របតាមនីតិវិធីដែលសមាគមអាចទទួលយល់ព្រមបាន ។

ភាគ ឃ : សេចក្តីសំរេចនៃការដេញថ្លៃ ពិនិត្យដោយសមាគម

១–ពិនិត្យលើការប្រកាសចូលរួមដេញថ្លៃ បញ្ញត្តិ និង កិច្ចសន្យាចុងក្រោយ :

(ក) ចំពោះកិច្ចសន្យានីមួយៗដែលត្រូវបានផ្គត់ផ្គង់តាមបទបញ្ញត្តិនៃភាគ ក–១ ខាងលើនិងចំពោះកិច្ចសន្យាពីរដំបូង ដែលត្រូវបានផ្គត់ផ្គង់តាមបទបញ្ញត្តិ នៃភាគ គ–១និង គ–២ ខាងលើនីតិវិធី ដែលចែងក្នុងកថាខ័ណ្ឌ២ និង ៤ ឧបសម្ព័ន្ធ១ នៃការណែនាំ ត្រូវបានអនុវត្ត ។ ក្នុងករណីដែលការទូទាត់កិច្ចសន្យាចេញពីគណនីពិសេស នីតិវិធីទាំងនេះត្រូវបានផ្លាស់ប្តូរដើម្បីធានាថា ឯកសារចម្លងត្រឹមត្រូវចំនួនពីរច្បាប់នៃកិច្ចសន្យា ដែលត្រូវផ្តល់អោយសមាគមសមស្របតាមកថាខ័ណ្ឌ២ (ឃ) ដែល បាននិយាយខាងលើត្រូវផ្តល់ជូនសមាគមមុននឹងធ្វើការទូទាត់លើកទី១ ពីគណនីពិសេសក្នុងការគោរព ទៅតាមកិច្ចសន្យានេះ ។

(ខ) ចំពោះកិច្ចសន្យានីមួយៗដែលមិនបានគ្រប់គ្រងដោយកថាខ័ណ្ឌ នីតិវិធីដែលបាន

ចែងនៅក្នុងកថាខ័ណ្ឌ៣ និង៤នៃឧបសម្ព័ន្ធ១ នៃ «ការណែនាំ» ត្រូវបានអនុវត្ត ។ ក្នុងករណីដែលការទូទាត់កិច្ចសន្យានេះធ្វើឡើងនៅក្រៅគណនីពិសេសនីតិវិធីទាំងនេះត្រូវបានផ្លាស់ ប្តូរដើម្បីធានាថាឯកសារចម្លង ត្រឹមត្រូវចំនួនពីរច្បាប់នៃកិច្ចសន្យាព្រមទាំងពត៌មានផ្សេងៗ ទៀតដែលត្រូវផ្តល់ជូនសមាគមសមស្រប តាមកថាខ័ណ្ឌ៣ ដែលបាននិយាយខាងលើ ត្រូវផ្តល់ជូនសមាគមទុកជាភស្តុតាងសមស្របតាមកថាខ័ណ្ឌ៤ នៃកម្មវិធី៤ របស់កិច្ចព្រមព្រៀងនេះ ។

(គ) បទបញ្ញត្តិនៃវាក្យខ័ណ្ឌ (ខ) ខាងលើមិនត្រូវបានអនុវត្តចំពោះកិច្ចសន្យាទាំងឡាយណាដែលការដកប្រាក់ពីគណនីឥណទាន គឺត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃស្ថានភាពចំណាយ ។

២–តួលេខចំនួនដប់ប្រាំភាគរយ (១៥%) ត្រូវបានកំណត់នៅទីនេះ ជាគោលបំណងនៃកថាខ័ណ្ឌ ៤ នៃឧបសម្ព័ន្ធ១ នៃការណែនាំ ។

ផ្នែក II–ការប្រើប្រាស់អ្នកពិគ្រោះ

១–ដើម្បីជួយជ្រោមជ្រែងអ្នកខ្ចីក្នុងកិច្ចអនុវត្តគំរោងការ អ្នកខ្ចីនឹងប្រើប្រាស់អ្នកពិគ្រោះដែលមានលក្ខណៈសម្បត្តិ បទពិសោធន៍ កាលកំណត់និងល័ក្ខខ័ណ្ឌនៃការងារត្រូវបំពេញទៅតាមសមាគម ។ អ្នកពិគ្រោះទាំងនេះត្រូវបានជ្រើសរើសសមស្របទៅតាមគោលការណ៍និងនីតិវិធីរបស់សមាគម ។ ដោយផ្អែកតាមការណែនាំនៃការប្រើប្រាស់អ្នកពិគ្រោះរបស់អ្នកខ្ចីនិងធនាគារពិភពលោកដែលជាភ្នាក់ងារអនុវត្តបោះពុម្ពផ្សាយដោយធនាគារ នៅខែសីហា ១៩៨១ (ការណែនាំអ្នកពិគ្រោះ) ។

២–ចំពោះកិច្ចការជ្រើសតាំងដ៏សាំញ៉ាំនេះ អ្នកខ្ចីជ្រើសរើសអ្នកពិគ្រោះទាំងនេះដោយធ្វើកិច្ចសន្យាតាមគំរូរបស់ធនាគារដែលអាចផ្លាស់ប្តូរបានតាមការព្រមព្រៀងជាមួយសមាគម ។ ក្នុងករណី ដែលគ្មានឯកសារកិច្ចសន្យាជាគំរូចេញដោយធនាគារនោះអ្នកខ្ចីអាចប្រើប្រាស់លិខិតគំរូផ្សេងទៀត ដោយមានការយល់ព្រមពីសមាគមផង ។

៣–ដោយបដិបញ្ញត្តិចំពោះកថាខ័ណ្ឌ១ នៃផ្នែកនេះ បទបញ្ញត្តិនៃការណែនាំអ្នកពិគ្រោះដែលតម្រូវអោយមានការត្រួតពិនិត្យពីសមាគម រឺយល់ព្រមថវិកា បញ្ជីរាយនាមរយៈពេលខ្លីសំរាំងនីតិវិធី លិខិតប្រកាសចូលរួម សំណើរបាយការណ៍វាយតំលៃព្រមទាំងកិច្ចសន្យាធានាមិនត្រូវបាន អនុវត្ត ចំពោះ : (ក) កិច្ចសន្យាជាមួយក្រុមហ៊ុនពិគ្រោះដែលមានតំលៃសមមូលតិចជាងមួយរយពាន់ដុល្លារ (១០០.០០០) ក្នុងមួយកិច្ចសន្យា រឺ (ខ) កិច្ចសន្យាជាមួយបុគ្គលពិគ្រោះដែល (ខ) តំលៃសមមូលតិច ជាងហាសិបពាន់ (៥០.០០០) ក្នុងមួយកិច្ចសន្យា ។

យ៉ាងណាក៏ដោយការលើកលែងនេះ ចំពោះការពិនិត្យជាមុនរបស់សមាគមមិនត្រូវបាន អនុវត្ត : (i) ល័ក្ខខ័ណ្ឌ បង្វែកនៃកិច្ចសន្យាទាំងនេះ (ii) ប្រភពជ្រើសរើសរោញពីក្រុមហ៊ុន តែមួយ (iii) កិច្ចការមាន លក្ខណៈកំណត់ សមហេតុសមផលពីសមាគម (iv) វិសោធន កម្មចំពោះកិច្ចសន្យាដែលធ្វើជាមួយក្រុមហ៊ុនពិគ្រោះ ដែលតំលៃកិច្ចសន្យាសមមូល ឬ ច្រើនជាងមួយរយពាន់ដុល្លារ (១០០.០០០) រឺ (v) វិសោធនកម្មចំពោះកិច្ចសន្យាជ្រើសរើស បុគ្គលពិគ្រោះ ដែលមានតំលៃកិច្ចសន្យាសមមូល រឺច្រើនជាងហាសិបពាន់ដុល្លារ (៥០.០០០)។

កម្មវិធី៤

គណនីពិសេស

១-គោលបំណងនៃកម្មវិធីនេះ

(ក) ពាក្យ « ប្រភេទជ្រើសតាំង »មានន័យថាប្រភេទ (១),(២),(៣),(៤) និង (៥) ដែល បានចែងក្នុងតារាងកថាខ័ណ្ឌ១ នៃកម្មវិធី១ ក្នុងកិច្ចព្រមព្រៀងនេះ ។

(ខ) ពាក្យ «ចំណាយជ្រើសតាំង» មានន័យថាចំណាយទៅតាមតម្លៃទំនិញ· និងសេវាដ៏សម ស្រប របស់គំរោងការ ហើយ ត្រូវបានហិរញ្ញសម្បទានពីចំនួនទឹកប្រាក់នៃគណនីពិសេស ផ្តល់អោយ «ប្រភេទជ្រើសតាំង» ជាបណ្តើរៗសមស្របតាមបទបញ្ញត្តិកម្មវិធី១ នៃកិច្ច ព្រមព្រៀងនេះ និង

(គ) ពាក្យ «ប្រាក់វិភាគយល់ព្រម» មានន័យថា ចំនួនប្រាក់សមមូលមួយលានដុល្លារ (១,០០០,០០០) ត្រូវបានដកចេញពី គណនីឥណទាន ហើយត្រូវបានតំកល់ក្នុងគណនី ពិសេស អនុលោមតាមកថាខ័ណ្ឌ ៣(ក) នៃ កម្មវិធីនេះ ។ ក៏ប៉ុន្តែបើពុំនោះទេ លុះ ត្រាតែសមាគមឯកភាព ប្រាក់វិភាគយល់ព្រមត្រូវបានកំរិតសមមូល បីរយពាន់ដុល្លារ (៣០០,០០០) រហូតដល់ទឹកប្រាក់សរុប ដែលត្រូវដកពីគណនីឥណទាន បូកចំនួនប្រាក់ សរុបដែលកំពុងស្ថិតនៅ ជាសន្យាពិសេសដោយធនាគារ អនុលោមតាមផ្នែក ៥,០២ នៃ «លក្ខខ័ណ្ឌទូទៅ » ស្មើនិងឬលើសចំនួនប្រាំពាន់ដុល្លារ (៥,០០០,០០០) ។

–បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តា ក្រសួងតាមឥណទានចែងក្នុងច្បាប់ហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៥

–បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥

–តាមសំណើរបស់ក្រសួងការពារជាតិ លេខ ១៥៧/៩៥ នថក ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិកា របស់ក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ នូវ ការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ :

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
១០	០២	០១		ការបង្វែរពីជំពូក ១០ បៀវត្សមូលដ្ឋានកងយោធពល	៩៦.៨៣៤.០០០	-	៥.០០០.០០០ ៥.០០០.០០០	៩១.៨៣៤.០០០
១០	០២	០៣	០៦	ផលប្រយោជន៍ជំពូក ១០ បំប៉នប្រយុទ្ធនិងអាហារប្រចាំថ្ងៃ	៦៣.៤៩៧.០០០	៥.០០០.០០០ ៥.០០០.០០០		៦៨.៤៩៧.០០០

ប្រការ ២ : ឯកឧត្តមសហរដ្ឋមន្ត្រី ក្រសួងការពារជាតិ ជាអ្នកទទួលបន្ទុកក្នុងការអនុវត្តន៍ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

ប្រកាស លេខ ៣១៣ សហវ.ឥ

ស្តីពីការណែនាំរៀបចំគំរោងថវិការដ្ឋឆ្នាំ ១៩៩៦

ដើម្បីធានាអោយការរៀបចំគំរោងថវិការដ្ឋឆ្នាំ ១៩៩៦ ប្រព្រឹត្តទៅតាមនីតិក្រម និងមានលក្ខណ: សុក្រឹត្យភាពនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចតទៅ ÷

គំរោងថវិការដ្ឋឆ្នាំ១៩៩៦ ត្រូវរៀបចំក្នុងក្របខ័ណ្ឌគោលដៅលំនឹងជាមូលដ្ឋាននៃម៉ាក្រូសេដ្ឋកិច្ចដែលមានតួលេខបញ្ជាក់ក្នុងតារាងដូចខាងក្រោមនេះ ÷

សមាមាត្រភាគរយនៃ ផសស (% GDP)

ទិន្នន័យសេដ្ឋកិច្ច និងថវិកាសំខាន់ៗ	ជាក់ស្តែង ឆ្នាំ ១៩៩៤	១៩៩៥		គំរោង ឆ្នាំ ១៩៩៦
		ដើមឆ្នាំ	កែតំរូវ	
_ផលិតផលក្នុងស្រុកសរុប–ផសស (GDS) (តាមករណី ពាន់លានរៀល)	៦១៣១	៧៦៤៧	៧០៥០	៨០៣៣
_អត្រាកំណើន ផសស (ថ្ងៃថេរ)	៤,០%	៧,៥%	៧,០%	៧,៥%
_អតិផរណា	១៧,៩%	១១,០%	៨,៧%	៥,០%
_អត្រាប្តូរប្រាក់ ៛/$	២៥៨៥	២៩០០	២៤០០	២៥០០
_<u>ចំណូលសរុប</u>	៩,៦%	៧,៦%	៩,៨%	៩,៥%
_គយ	៤,៦%	៤,៨%	៤,៩%	៤,៩%
_ពន្ធដារ	១,៣%	១,២%	១,៧%	២,៥%
_ចំណូលពុំមែនសារពើពន្ធ	៣,៧%	១,៦%	៣,២%	២,១%
_<u>ចំណាយសរុប</u>	១៦,៣%	១៣,៨%	១៨,២%	១៦,៥%
_ចំណាយជាប្រចាំ	១០,៨%	៨,៨%	១១,២%	១០,២%
_ចំណាយការពារជាតិ និងសន្តិសុខ	៦,៤%	៤,០%	៥,៩%	៤,៩%
_ចំណាយជាមូលធន	៥,៥%	៥,០%	៦,២%	៦,៤%
_និនភាពជាប្រចាំ	-១,២%	-១,២%	-១,៤%	-០,៧%
_និនភាពសរុប	-៦,៧%	-៦,២%	-៧,៦%	-៧,១%
_ហិរញ្ញប្បទានពីក្រៅប្រទេស	៦,៧%	៦,១%	៨,៣%	៦,៩%

ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលបានបញ្ជាក់ ក្នុងតារាងខាងលើនេះ គឺកសាងឡើងដោយផ្អែកលើបណ្តា ទិន្នន័យ ដែលបានអនុវត្តជាក់ស្តែងក្នុងឆ្នាំ១៩៩៤ ការប៉ាន់ស្មានអនុវត្តឆ្នាំ១៩៩៥ និង និទស្សន៍សំរាប់ឆ្នាំ១៩៩៦ ។

១–<u>ចំណូលថវិការដ្ឋ</u> :

គ្រប់គ្រងស្ថាប័នដែលមានចំណូល ត្រូវធ្វើគំរោងចំណូលសំរាប់ឆ្នាំ ១៩៩៦ ដែលរួម

មានទាំងរដ្ឋបាល កណ្តាល និង ខេត្ត-ក្រុង ទៅតាមលំដាប់លំដោយ នៃតារាងរាយនាមថវិកា ដូចមានភ្ជាប់មកជាមួយនេះ ។

ដោយឡែក នាយកដ្ឋានពន្ធដារ ទីចាត់ការគយ នាយកដ្ឋានហិរញ្ញកិច្ច និង នាយកដ្ឋានទ្រព្យរដ្ឋ ត្រូវធ្វើតំរោងចំណូលសរុប និង តំរោងចំណូលលំអិតតាមខេត្ត-ក្រុង នីមួយៗ ដើម្បីដាក់ឆ្លងការពិនិត្យ សំរេចពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយផ្ញើជូននាយកដ្ឋានថវិការដ្ឋយ៉ាងយូរបំផុតថ្ងៃទី ១៥ កញ្ញា ឆ្នាំ ១៩៩៥ ។

២-ចំណាយថវិការដ្ឋ :

ចំណាយ ត្រូវគ្រោងគិតដោយផ្អែកលើតំរូវការចាំបាច់របស់ក្រសួងទាំងមូល ដែលរួមមានទាំងរដ្ឋបាលកណ្តាល និង មន្ទីរជំនាញនៅខេត្ត-ក្រុង ហើយត្រូវឈរលើគោលការណ៍សន្សំសំចៃកាត់បន្ថយនូវចំពាយមិនទាន់ចាំបាច់ និង រៀបរាប់បញ្ជាក់អោយបានច្បាស់លាស់អំពីមុខចំណាយសំខាន់ៗ ដែលជាតំរូវការចាំបាច់បំផុត ដើម្បីធានាអោយសរុបចំណាយថវិការដ្ឋទាំងមូលស្ថិត នៅក្នុងកំរិតមួយ សមស្របទៅនឹងលទ្ធភាពដែលប្រទេសជាតិអាចដោះស្រាយបាន ។

គ្រប់ក្រសួង និង មន្ទីរជំនាញទាំងអស់នៅតាមខេត្ត-ក្រុង ត្រូវយល់ឃើញថា ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ ១៩៩៤ និង ឆ្នាំ ១៩៩៥ គឺមានប្រភពហិរញ្ញប្បទានពីជំនួយក្រៅប្រទេសសឹងតែស្មើនឹង ៥០ ភាគរយ ដើម្បីធានាការចំណាយជាប្រចាំ និង ចំណាយជាមូលធន ។ ថ្វីត្បិតតែប្រភពហិរញ្ញប្បទានពីជំនួយ ក្រៅប្រទេស នៅតែមានបន្តក្នុងឆ្នាំ ១៩៩៦ ក៏ដោយ ក៏វាមិនអាចមានជារៀងរហូតនោះទេ ។ ដូច្នេះ បើយើងចេះតែបង្កើន ការចំណាយដោយគ្មានការគិតគូរពិចារណាដល់តុល្យភាពថវិកានោះ ផលវិបាកនឹងជំរុញអោយរូបិយវត្ថុចុះខ្សោយ ហើយសេដ្ឋកិច្ចជាតិធ្លាក់ទៅក្នុងស្ថានភាពអតិផរណាដោយឥតឈប់ឈរ ។

ស្ថិតក្នុងក្របខ័ណ្ឌទស្សនៈរៀបចំថវិកាដូចខាងលើនេះ ការចំណាយថវិកាក្នុងឆ្នាំ ១៩៩៦ ត្រូវយកចិត្ត ទុកដាក់អនុវត្តនូវចំណុចសំខាន់ និង ជាអាទិភាពដូចតទៅ :

-អំពីចំណាយការពារជាតិ និង សន្តិសុខក្នុងឆ្នាំ ១៩៩៤ និង ឆ្នាំ ១៩៩៥ យើងបានទប់ចំណាយនេះ អោយនៅក្នុងកំរិតពី ៦ ទៅ ៧ ភាគរយ នៃផលិតផលក្នុងស្រុកសរុប ផសស ហើយក្នុងឆ្នាំ ១៩៩៦ ត្រូវបន្ថយមកតិចជាង ៥ ភាគរយ នៃ ផសស តែប៉ុណ្ណោះ ដើម្បីអោយសមស្របទៅតាមលក្ខណៈវិនិច្ឆ័យរបស់មូលនិធិ រូបិយវត្ថុអន្តរជាតិ គឺមិនលើសពី ៤០០ ពាន់លានរៀល ។

-ចំពោះវិស័យអប់រំ និង សុខាភិបាល រាជរដ្ឋាភិបាលមានគោលការណ៍លើកកំពស់

ទាំងបរិមាណ និង គុណភាព ។ ដូច្នេះចំណាយចរិកាលើវិស័យទាំងពីរនេះ ត្រូវបានបង្កើន ស្របទៅនឹងកំណើននៃ ផសស ដែល គ្រោងគិតក្នុងឆ្នាំ ១៩៩៦ ប្រហែល ១៤ ភាគរយ ហើយសមាមាត្រនេះ នឹងត្រូវបង្កើនអោយបានប្រហាក់ប្រហែល នឹងបណ្តាប្រទេសជិតខាងដែល នៅជុំវិញយើងនាឆ្នាំ ២០០០ ។

–អំពីចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច គឺត្រូវគ្រោងក្នុងកំរិត នៃតួលេខចាំន់ស្មានអនុវត្តជាក់ស្តែងក្នុងឆ្នាំ ១៩៩៥ ។ ដូច្នេះគ្រប់ក្រសួង និង មន្ទីរជំនាញ នៅខេត្ត–ក្រុង ទោះបីមានតំរូវការ ចាំបាច់ថ្មីៗទៀតក៏ដោយ ក៏ត្រូវគិតគូររៀបចំសំរបសំរួលចរិកា នៅក្នុងរង្វង់ក្របខ័ណ្ឌនៃកំរិតកំណត់នេះ ។

–ចំពោះចំណាយទុនវិនិយោគ និង ចំណាយដោយឡែករបស់ផ្នែក ត្រូវគ្រោងទុកនៅ ថ្នាក់រដ្ឋបាលកណ្តាល ដែលក្រសួងនីមួយៗ ត្រូវពិនិត្យបែងចែកអោយទៅមន្ទីរជំនាញនៅតាម ខេត្ត–ក្រុង ដើម្បីអនុវត្តគោលនយោបាយ ក្នុងវិស័យរបស់ខ្លួនហើយ ចំណាយដោយឡែករបស់ ផ្នែកដែលមានខ្លឹមសារដូចចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូចជាទូទៅ នោះ មិនត្រូវគ្រោងចូលក្នុងចំណាយដោយឡែករបស់ផ្នែកឡើយ គឺត្រូវគ្រោងចូលក្នុងបណ្តាវិភាគ ខ័ណ្ឌ នៃចំណាយដំណើរការរដ្ឋបាល សំភារៈ និង ជួសជុលតូច ដូចជាប្រេង ឥន្ធនៈ ក្នុងការ ផ្សាយវិទ្យុទូរទស្សន៍ បោះពុម្ពឯកសារជំនាញ ។ល។

–ដោយឡែកអំពីចំនួនក្របខ័ណ្ឌមន្ត្រីរាជការ នៅក្នុងឆ្នាំ ១៩៩៦ ដោយគោរពទៅតាម កិច្ចសន្យារវាងរាជរដ្ឋាភិបាល និង មូលនិធិរូបិយវត្ថុអន្តរជាតិ គ្រប់ក្រសួង ស្ថាប័ន ត្រូវប្រឹងប្រែង កាត់បន្ថយអោយបានយ៉ាងតិច ១០ ភាគរយ នៃក្របខ័ណ្ឌជាក់ស្តែងដែលមានក្នុងឆ្នាំ ១៩៩៥ ។

–តួលេខគំរោងចំណូលចំណាយ ដែលបានគ្រោងនៅគ្រប់វិភាគខ័ណ្ឌទាំងអស់ត្រូវ មាន មូលដ្ឋានពិតប្រាកដដើម្បីពន្យល់បញ្ជាក់បំភ្លឺ នៅពេលដែលក្រសួងនីមួយៗ ឡើងមកការពារ គំរោងនាពេលពិភាក្សាជាមួយ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយឥណទានចំណាយណា ដែលគ្មានមូលដ្ឋានបញ្ជាក់ត្រឹមត្រូវទេនោះ នឹង ត្រូវកាត់ចេញដោយស្វ័យប្រវត្តិ ។

–គ្រប់មន្ទីរជំនាញនៅតាមខេត្ត–ក្រុងទាំងអស់ ត្រូវធ្វើគំរោងចំណូលចំណាយចរិកា របស់ខ្លួន ដោយមានចុះហត្ថលេខា និង បោះត្រាបញ្ជាក់ពីមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អភិបាលខេត្ត–ក្រុង ហើយផ្ញើជូន ក្រសួងសាមីអាណាព្យាបាលចំនួន ២ ច្បាប់ ។

–គ្រប់ក្រសួងទាំងអស់ ត្រូវរៀបចំគំរោងចំណាយចរិការបស់ខ្លួន ដោយផ្តើមចេញ អំពីកម្មវិធីសកម្មភាព (Programme d'activité) នៃការងារជំនាញនីមួយៗ (ចំពោះការងារ ណាដែលមានគោលដៅច្បាស់លាស់) ដើម្បីបង្កើតឡើងនូវគំរោង ចំណាយចរិកាសរុបរបស់ខ្លួន

ទៅតាមតារាងរាយនាមថវិកា និង តារាងបញ្ជាក់លំអិត ដូចមាន ភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

–តួលេខនៃគំរោងចំណូលចំណាយថវិកា ត្រូវសរសេរជាលេខអន្តរជាតិ (1.2.3...) ហើយឯកត្តាគិតទាបបំផុតពី ០,១ លានរៀល ។

គ្រប់ក្រសួងទាំងអស់ ត្រូវយកចិត្តទុកដាក់ខិតខំរៀបចំគំរោងថវិកាសំរាប់ឆ្នាំ ១៩៩៦ អោយបានត្រឹមត្រូវ និង ទាន់ពេលវេលា តាមខ្លឹមសារនៃសេចក្តីប្រកាសនេះ ក្នុងករណីមានបញ្ហាណានៅស្មុគស្មាញ ត្រូវមកទំនាក់ទំនងដោះស្រាយជាបន្ទាន់ ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ទេសរដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
គាតឈន់

២_ធនាគារជាតិ នៃកម្ពុជា

ប្រកាស

ភ្នំពេញ ,ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ធ ៩៩៥-១២០ ប្រក

ស្តីពីការប្រគល់សិទ្ធិចុះហត្ថលេខាលើប្រតិទេនទំនៃការនាំចេញ នាំចូល រូបិយប័ណ្ណ និងលោហធាតុ ត្បូងថ្មមានតំលៃ

= = =

អគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់សម្តេចព្រះបាទ**នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ធ្វើនៅថ្ងៃទី១១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការរក្សាទុកនូវតំណែងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាដែល

–បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២២-៦-៩២ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃធនាគារជាតិនៃកម្ពុជា

សំរេច

ប្រការ១ :ប្រគល់សិទ្ធិអោយនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ ពិនិត្យ និងចុះហត្ថលេខាលើប្រតិវេទន៍នៃការនាំចេញ នាំចូល រូបិយប័ណ្ណ និងលោហធាតុ ត្បូងថ្មមានតំលៃ ។

ប្រការ២ :ប្រតិវេទន៍នីមួយៗនឹងចាត់ទុកជាបានការ លុះត្រាតែមានហត្ថលេខារួមគ្នានៃមន្ត្រី ២ រូបរបស់នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់គឺ ÷

– ប្រធាននាយកដ្ឋាន ឬ អនុប្រធាននាយកដ្ឋានភ្ជាប់រួម
– អនុប្រធាននាយកដ្ឋានណាមួយ ១រូបទៀត

ប្រការ៣ :ក្នុងករណីពិនិត្យឃើញភាពមិនប្រក្រតីក្នុងប្រតិវេទន៍ ត្រូវរាយការណ៍ និងសុំសេចក្តីសំរេចពីថ្នាក់ដឹកនាំខ្ពស់ជាងនៃធនាគារជាតិ ។

ប្រការ៤ : នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងបណ្តានាយកដ្ឋានក្រោមឱវាទធនាគារជាតិដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

ប្រការ៥ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អគ្គទេសាភិបាលនៃធនាគារជាតិ
ហត្ថលេខានិងត្រា
ថៅ ចេងឈាត

៣_ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

ភ្នំពេញ,ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ៦៧៥ ឧល,ប្រក

ស្តីពីការផ្ទេរ និង សំរួលភារកិច្ច មន្ត្រី រាជការ

រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្មរ៉ែ និងថាមពល

–បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តមសីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជ រដ្ឋាភិបាលកម្ពុជា

–បានឃើញប្រកាសលេខ : ៦៧១ បល.ប្រក ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការ ប្រគល់ ការគ្រប់គ្រងទីតាំងនៃទីស្នាក់ការក្រុមហ៊ុនសំភារៈ និងដឹកជញ្ជូន ជូនក្រុមហ៊ុនឯកជនគ្រប់គ្រង

–ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង ។

សំរេច

ប្រការ១ : ផ្ទេរនិងសំរួលភារកិច្ចមន្ត្រីរាជការក្រុមហ៊ុនសំភារៈ និងដឹកជញ្ជូន ដូចមានរាយនាម ខាងក្រោមនេះ ÷

១–លោក **ង៉ែន សារិទ្ធ**	ពីប្រធានក្រុមហ៊ុនសំភារៈ និងដឹកជញ្ជូនអោយមកធ្វើជា អនុប្រធាននាយកដ្ឋានបច្ចេកទេស ដោយរក្សាកាំប្រាក់ បៀវត្សនៅដដែល
២–លោក **យូ គីមសាន**	ពីអនុប្រធានការិយាល័យចាត់តាំងបៀវត្សពលកម្ម មកធ្វើជាមន្ត្រីធម្មតានៅនាយកដ្ឋានបុគ្គលិកដោយ រក្សាកាំបៀវត្សនៅដដែល
៣–លោក **ឡុញ សាទី**	ពីអនុប្រធានអង្គភាពឃ្លាំងសំភារៈភ្នំពេញ មកធ្វើជា មន្ត្រីធម្មតានៅមន្ទីរ នៃទីស្តីការដោយរក្សាកាំបៀវត្ស នៅដដែល
៤–លោក **នាយ ខន**	ពីអនុប្រធានអង្គភាពឃ្លាំងសំភារៈភ្នំពេញ មកធ្វើជា មន្ត្រីធម្មតានៅនាយកដ្ឋានបច្ចេកទេស ដោយរក្សា កាំបៀវត្សនៅដដែល
៥–កញ្ញា **ប្រាក់ គីមឡេង**	ពីអនុប្រធានការិយាល័យ គណនេយ្យ-ហិរញ្ញកិច្ច មកធ្វើជាមន្ត្រីធម្មតានៅនាយកដ្ឋានគណនេយ្យ ហិរញ្ញកិច្ច ដោយរក្សាកាំបៀវត្សនៅដដែល

ប្រការ២ : រាល់សេចក្តីសំរេច លិខិតបង្គាប់ការពីមុនដែលមានចំណុចពាក់ព័ន្ធ និងសាមីជនដូច

មានចែងក្នុងប្រការ១ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៣ : លោកប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានបច្ចេកទេស និងអស់លោក-កញ្ញាទាំង០៥រូបខាងលើ មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួន តាមប្រកាសនេះ ។

ប្រការ៤ :ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ពូ សុធីរៈ

ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ៦៧៦ ឧក,ប្រក

ប្រការ១ : អនុញ្ញាតអោយលោក **ទិញ ធ្វី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១០០៤៥៧ ភ.ព ចុះថ្ងៃទី ១៩ -៨ - ៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៧៤ សង្កាត់ ច្បារអំពៅទី១ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ បើកដំណើរការរោងឧស្សាហកម្ម ផលិតប្រេងរំអិល (COSMIC) នៅក្នុងទីតាំង ភូមិទឹកជា ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល ។

ប្រការ២:លោក **ទិញ ធ្វី** ត្រូវរៀបចំមូលដ្ឋានផលិតកម្មរបស់ខ្លួនអោយរួចស្រេចជាស្ថាពរ ក្នុងរយៈពេល ៦ខែ គិតចាប់តាំងពីថ្ងៃចុះហត្ថលេខាលើប្រកាសនេះតទៅ ។ ហួសរយៈពេលកំណត់ប្រកាសនេះ ត្រូវចាត់ទុកជាមោឃៈ ។

ប្រការ៣ :ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងឧស្សាហកម្ម ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិដ្ឋាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ៤ :ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រកាសលេខ : ៦៧៧ ផក.ប្រក ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ១ : អនុញ្ញាតអោយលោក ពេញ **សាយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០០០៣០៦ កស្ត ចុះថ្ងៃទី ០៩ -១១ - ៨៤ អាស័យដ្ឋានបច្ចុប្បន្ន ភូមិឧដុង្គ ឃុំវាំងចាស់ ស្រុក ឧត្តុង្គ ខេត្ត កំពង់ស្ពឺ បើកដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងទីតាំង ភូមិស្រះកែវ ឃុំវាំងចាស់ ស្រុក ឧដុង្គ ខេត្តកំពង់ស្ពឺ ។

ប្រការ២ :ប្រកាសនេះមានតំលៃក្នុងពេលក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្ករអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ : ៦៧៨ ផក.ប្រក ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ១ : អនុញ្ញាតអោយលោក **គង់ ចាសនា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២៩៤១៥ សរ ចុះថ្ងៃទី ១០ - ៧ - ៨៨ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី៥ ភូមិអន្លង់វិល ឃុំ គោកចួកក្រោម ស្រុកជីក្រែង ខេត្ត សៀមរាប បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ២ : លោក **គង់ ចាសនា** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ភាគរយ ។

ប្រការ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ : ៦៧៩ ផក.ប្រកចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ១ : អនុញ្ញាតអោយលោក **ស៊ុម គុត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ

លេខ ០៥៤៨៧២ ប.ជ ចុះថ្ងៃទី ០១ - ១២ - ៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ទួលរការ ឃុំ ឫស្សីក្រាំង ស្រុកមោងឫស្សី ខេត្ត បាត់ដំបង បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០សេះ នៅក្នុងទីតាំង ភូមិកាលោមភុក ឃុំព្រៃស្វាយ ស្រុកមោងឫស្សី ខេត្ត បាត់ដំបង ។

ប្រការ២ :លោក **ស៊ុម គុក** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែល បានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ : ៦៨០ ឧក.ប្រក ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ១ :អនុញ្ញាតអោយលោក **សុខ សេខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៨៨០៧៩ គ.ក ចុះថ្ងៃទី ២៧ - ៨ - ៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិត្រពាំងអង្គ ឃុំកំពែង ស្រុកព្រៃកប្បាស ខេត្ត តាកែវ បើកដំណើរការ រោងម៉ាស៊ីនផលិតទឹកកក ដើម នៅក្នុងទីតាំង ភូមិលំចង់ ឃុំ លំចង់ ស្រុកសំរោង ខេត្ត តាកែវ ។

ប្រការ២ :ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវ ធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស ច្បាប់ ផលិតផលគ្មាន គុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិដ្ឋានប្រកាស នេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ : ៦៨១ ឧក.ប្រក ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ១ : អនុញ្ញាតអោយអ្នកស្រី **ពួន ឡាក់នូ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ៣០២០៨១ ភ.ព ចុះថ្ងៃទី ៣១-១២-៩១ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៦ ផ្លូវលេខ ៤១ សង្កាត់ ទន្លេបាសាក់ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញបន្តដំណើរការ សិប្បកម្មផលិតថ្នាំលាប សក់នៅក្នុងទីតាំង ផ្ទះលេខ ៤០ ផ្លូវលេខ ១២៦ សង្កាត់

ផ្សារថ្មីទី១ ខណ្ឌ ដូនពេញ រាជធានី ភ្នំពេញ ។

ប្រការ២ :អ្នកស្រី **ពួច ឡាក់នួ** ត្រូវអនុញ្ញាតអោយផលិតនូវមុខផលិតផល ដូចតទៅ ÷ ថ្នាំលាបសក់ «PEACOCK I-G» , ថ្នាំលាបសក់ «PAON SEVEN-EIGHT» និងថ្នាំលាបសក់ «PEACOCK» ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុក នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាស នេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ពូ សុធីរៈ

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ៦៨៩ ចល.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសំណើសុំ លេខ ០៩ លស ៩៥ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់អគ្គាធិការដ្ឋាន
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ១:តែងតាំងមន្ត្រីរាជការ ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោមនេះ ជាប្រធាន អនុប្រធានការិយាល័យនៃអគ្គាធិការដ្ឋាន ÷

១-លោក **កែវ ស៊ិន** ជាប្រធាន ការិយាល័យអធិការដ្ឋានរដ្ឋបាល

២-លោក **សាន សមុទ្រ** ជាប្រធាន ការិយាល័យអធិការដ្ឋានបច្ចេកទេស

៣–លោក ម៉ៅ សេដ្ឋា ជាអនុប្រធាន ការិយាល័យអធិការដ្ឋានហិរញ្ញវត្ថុ

ប្រការ២ :រាល់សេចក្តីសំរេច លិខិតបង្គាប់ការពីមុនដែលមានចំណុចពាក់ព័ន្ធនឹងអស់លោក ដូចមានចែងក្នុងប្រការ ១ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៣:លោកនាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ–ហិរញ្ញកិច្ច អគ្គាធិការនៃអគ្គាធិការដ្ឋាន និង អស់លោកទាំង ០៣ រូប ខាងលើ មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

ប្រការ៤ :ប្រកាសនេះមានប្រសិទ្ធភាព អនុវត្តចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ព្ញ សុធីរៈ

៤_ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៩៣/៩៥ ពម.ប្រក

ស្តីពីការលុបឈ្មោះមន្ត្រីរាជការ

ចេញពីក្របខ័ណ្ឌ ក្រសួង

–បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃ ទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

–បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា

–បានឃើញអនុក្រឹត្យស្តីពីការកែលំអរបៀបរៀប កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២

–យោងតាមសំណើរបស់អគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានខ្មែរ លេខ ២១១ សពខ ចុះថ្ងៃទី ១៩–៧–១៩៩៥

-ពិនិត្យលើសំណូមពររបស់សាមីខ្លួន

សម្រេច

ប្រការ១ : លុបឈ្មោះមន្ត្រីរាជការ ចំនួន ០២ រូប ចេញពីក្របខ័ណ្ឌ អគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានខ្មែរនៃ ក្រសួងពត៌មាន ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៥ នេះទៅ ដែលមានឈ្មោះដូចខាងក្រោមនេះ ÷

១-លោក **ឡូច សារមេត្ត**	ប្រធានការិយាល័យ	ចូលបំរើការងារ ២៣-១០-១៩៨០
២-លោក **ជា ទិមុល**	បុគ្គលិក	ចូលបំរើការងារ ០១-១០-១៩៨៧

ប្រការ២ :ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន ត្រូវបានទទួលម្តងគត់គឺស្មើនឹងប្រាក់បៀវត្សសរុបក្នុង ១ ខែ គុណនឹងចំនួនឆ្នាំបំរើការងារ ដូចជា ÷

១-លោក **ឡូច សារមេត្ត** : ៤៨.២៣០៛ គុណ ១០ = ៤៨២.៣០០៛០០

២-លោក **ជា ទិមុល** : ៣៣.៨០០៛ គុណ ០៨ = ២៧០.៤០០៛០០

ប្រការ៣ :អគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានខ្មែរ នាយកដ្ឋានរដ្ឋបាល-បុគ្គលិក នាយកដ្ឋានគណនេយ្យផែនការ ហិរញ្ញកិច្ច និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៩៥/៩៥ ពម.ប្រក

ស្តីពីការទទួលស្គាល់លោក ឆាំង ឆន

ជាមន្ត្រីរាជការរបស់ក្រសួងពត៌មាន

* * * * * *

-យោងព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

-បានឃើញអនុក្រឹត្យ លេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

-យោងចំណារបញ្ជូន លេខ ៤៥៨ សស ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់មន្ទីរពត៌មាន រាជធានីភ្នំពេញ

សំរេច

ប្រការ១ : ទទួលស្គាល់លោក **ឈិន ឆន** ជាមន្ត្រីរាជការនៃមន្ទីរពត៌មាន រាជធានីភ្នំពេញ អោយមកបំរើការងារនៅក្រសួងពត៌មាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រការ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីជន ត្រូវទទួលនៅក្រសួង ពត៌មាន គិតចាប់ពីពេលដែលមន្ទីរពត៌មានរាជធានីភ្នំពេញផ្ទេរមកអង្គភាពថ្មី ។

ប្រការ៣ : អគ្គនាយកដ្ឋានរដ្ឋបាលនិង ហិរញ្ញវត្ថុ មន្ទីរពត៌មានរាជធានីភ្នំពេញ លោក **ឈិន ឆន** ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
អៀង មូលី

រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ២០៨.៩៥ ពម.ប្រក

ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង

– បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រម លេខ ០៦ន.ស ចុះថ្ងៃទី ៣០ ខែ ១០ ឆ្នាំ ១៩៩៤ ស្តីពី ការអោយប្រើសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

– បានឃើញអនុក្រឹត្យ ស្តីពីការកែលំអបៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ

លេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២

- យោងតាមរបាយការណ៍របស់ទីភ្នាក់ងារសារពត៌មានខ្មែរ លេខ ២១៥ ស.ព.ខ ចុះថ្ងៃទី ២៦ ខែ ៧ ឆ្នាំ ១៩៩៥
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន កាសែតកម្ពុជា លេខ ៨០ កសក.មល ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : លុបឈ្មោះមន្ត្រីរាជការចំនួន ០២ នាក់ ចេញពីក្របខ័ណ្ឌ ក្រសួងពត៌មាន ដែល មានសមាសភាពដូចខាងក្រោម ÷

១–លោក **ល្មុយ ជាតិត** បំរើការងារនៅអគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានខ្មែរ

២–លោក **ឃឹម សុគា** បំរើការងារនៅអគ្គនាយកដ្ឋានកាសែតកម្ពុជា

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួនត្រូវផ្តាច់ចេញពីតារាង បៀវត្សរបស់អគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានខ្មែរ និង អគ្គនាយកដ្ឋាន កាសែតកម្ពុជា នៃក្រសួងពត៌មាន ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៥ តទៅ ។

ប្រការ ៣ : អគ្គនាយកដ្ឋាន ទីភ្នាក់ងារសារពត៌មានខ្មែរ អគ្គនាយកដ្ឋាន កាសែតកម្ពុជា អគ្គនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

៥_ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៥២ ប្រក.វវស.ម

ស្តីពីការផ្ទេរក្របខ័ណ្ឌ

* * * * * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញលិខិតរបស់ក្រសួងសុខាភិបាល លេខ ២០១០ សកប ចុះថ្ងៃទី ១៦-៨-១៩៩៥ ស្តីពីការទទួលយកលោក **ម៉ម តែល** អោយបំរើការងារក្នុងក្រសួងសុខាភិបាល

សំរេច

មាត្រា ១ : លោក **ម៉ម តែល** បច្ចុប្បន្នជាបុគ្គលិកនាយកដ្ឋានបុគ្គលិក ត្រូវបានអនុញ្ញាតអោយផ្លាស់ទៅបំរើការងារនៅ ក្រសួងសុខាភិបាល ។

មាត្រា ២ : ក្រសួងនឹងផ្ទេរប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន ព្រមទាំងក្របខ័ណ្ឌ ០១ កន្លែង ជូនក្រសួងសុខាភិបាល ។

មាត្រា ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស និង លោក **ម៉ម តែល** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ព្រះហស្តលេខា និង ត្រា

ស៊ីសុវត្ថិ ស៊ីវុធ ប៉ាណារ៉ា

៦_ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៣៤០ អយក. ប្រក

ស្តីពីការផ្លាស់សាលាបឋមសិក្សាស្រែពោធិ ឧបសម្ព័ន្ធសាលាបឋមសិក្សាស្ទឹងត្រែងអោយទៅជា «សាលាបឋមសិក្សាឃុំស្រះឫស្សី»

រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១–១១–១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៨៦ ស្តីពីការកំនត់បទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពនានា
- បានឃើញក្រឹត្យច្បាប់លេខ ៣០. ក្រច ចុះថ្ងៃទី ២០–១១–១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- បានពិនិត្យលិខិតលេខ ៦ អយកខ. ចទម ចុះថ្ងៃទី ១៣–៥–១៩៩៥ របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្តស្ទឹងត្រែង
- តាមយោបល់ឯកភាព របស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និង កីឡា ខេត្តស្ទឹងត្រែង ផ្លាស់សាលាបឋមសិក្សាស្រែពោធិ ឧបសម្ព័ន្ធសាលាបឋមសិក្សា ស្ទឹងត្រែង មកជាសាលាបឋមសិក្សាស្រះឫស្សី ចាប់ពីឆ្នាំសិក្សា ១៩៩៤–១៩៩៥ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សា ស្រះឫស្សី ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា។

ប្រការ ៣ : នាយក និង នាយករងមានសិទ្ធិទទួលប្រាក់ចំណាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

ប្រការ ៤ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការ-ហិរញ្ញកិច្ច នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា មន្ទីរអប់រំយុវជន និង កីឡាខេត្តស្ទឹងត្រែង ការិយាល័យអប់រំយុវជន និង កីឡាស្រុកស្ទឹងត្រែង និងសាលាបឋមសិក្សាស្រះឫស្សី មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
តុល ឡោះ

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៣៤១ អយក.ប្រក

* * * * *

ស្តីពីការផ្លាស់សាលាឧបសម្ព័ន្ធមកជាសាលាបឋមសិក្សា

ពេញលក្ខណ:

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១-១១-១៩៩៣
  ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណា ចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-១៩៩៤

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៨៦ ស្តីពីការកំណត់បទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពអប់រំនានា
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានពិនិត្យលិខិតស្នើសុំ របស់ការិយាល័យអប់រំ យុវជន និង កីឡាទីរួមខេត្តព្រៃវែង ក្នុងខេត្តព្រៃវែង លេខ ០២-៩៥ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៥
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយការិយាល័យអប់រំយុវជននិងកីឡា ទីរួមខេត្តព្រៃវែង ក្នុងខេត្តព្រៃវែង ផ្តាច់សាលាឧបសម្ព័ន្ធ អោយទៅជាសាលាបឋមសិក្សាពេញលក្ខណៈ ÷

១-សាលាបឋមសិក្សា ប្រាំងទទឹង ឧបសម្ព័ន្ធសាលាបឋមសិក្សាព្រែកផ្តាំ ទៅជាសាលា បឋមសិក្សា ប្រាំងទទឹង

២-សាលាបឋមសិក្សា ស្វាយសុខោ ឧបសម្ព័ន្ធរបស់សាលាបឋមសិក្សាពោធិ៍ដីរ ទៅជាសាលាបឋមសិក្សា ស្វាយសុខោ

៣-សាលាបឋមសិក្សា វត្តស្វាយ ឧបសម្ព័ន្ធរបស់សាលាបឋមសិក្សាព្រែកខ្លោង ទៅជាសាលាបឋមសិក្សា វត្តស្វាយ

ប្រការ ២ : សាលាបឋមសិក្សាដូចមានរាយនាមខាងលើ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក និងនាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់ រដ្ឋ ។

ប្រការ ៤ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការ-ហិរញ្ញកិច្ច នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា មន្ទីរអប់រំយុវជន និងកីឡាខេត្តព្រៃវែង និង សាលាបឋមសិក្សាដូចមានរាយនាមខាងលើ មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

គុល ឡោះ

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៣៤២ អយក.ប្រ.ក

ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ មកជាសាលាបឋម

សិក្សាពេញលក្ខណៈ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។

_បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-១៩៩៤ ។

_បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥-១០-១៩៨៦ ស្តីពីការកំណត់បទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពនានា ។

_បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ។

_បានពិនិត្យលិខិតរបស់ការិយាល័យអប់រំ យុវជន និកីឡាស្រុកបាភ្នំលេខ ២៦៤-៩៤ អយក.បក ចុះថ្ងៃទី ៩-១២-១៩៩៤ ។

_តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយការិយាល័យអប់រំ យុវជន និងកីឡា ស្រុកបាភ្នំ ខេត្ត ព្រៃវែង ផ្តាច់សាលាឧបសម្ព័ន្ធ អោយទៅជាសាលាបឋមសិក្សាពេញលក្ខណៈ

១_សាលាបឋមសិក្សាព្រៃទំពូង ជាឧបសម្ព័ន្ធសាលាបឋមសិក្សាសីរសន្ធាយ ទៅជាសាលាបឋមសិក្សាព្រៃទំពូង ក្នុងឃុំធាយ ។

២_សាលាបឋមសិក្សាព្រះរាជមានជ័យ ឧបសម្ព័ន្ធសាលាបឋមសិក្សាជ្រួលថ្មី ទៅជាសាលាបឋមសិក្សាព្រះរាជមានជ័យ នៅឃុំរក្សជ័យ ។

៣_សាលាបឋមសិក្សាស្នេហ៍រាន ឧបសម្ព័ន្ធសាលាបឋមសិក្សាប្រស្រែ ទៅជាសាលាបឋមសិក្សាស្នេហ៍រាន ក្នុងឃុំបឹងព្រះ ។

៤_សាលាបឋមសិក្សាកោះជ្រុំ ឧបសម្ព័ន្ធសាលាបឋមសិក្សាស្តី ទៅជាសាលាបឋមសិក្សាកកោះជ្រុំ ក្នុងឃុំស្តី ។

ប្រការ ២ :សាលាបឋមសិក្សាដែលមានរាយនាមខាងលើនេះ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់បឋមសិក្សា ។

ប្រការ ៣ : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ ៤ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការ ហិរញ្ញកិច្ច នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង ការិយាល័យអប់រំ យុវជន និងកីឡាស្រុក បាភ្នំ និងសាលាបឋមសិក្សាដូចមានរាយនាមខាងលើ មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

តុល ឡោះ

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៣៤៣ អយក.ប្រក

ស្តីពីការផ្លាស់សាលាឧបសម្ព័ន្ធ

មកជាសាលាបឋមសិក្សា ពេញលក្ខណៈ

* * * * * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេច ព្រះ នរោត្តម សីហនុវរ្ម័ន

ព្រះចៅក្រុងកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-១៩៩៤
- បានឃើញអនុក្រឹត្យ លេខ ១៩ អនក្រ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៨៦ ស្តីពីការកំនត់បទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពនានា
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានពិនិត្យលិខិតស្នើសុំរបស់ការិយាល័យអប់រំ យុវជន និង កីឡា ស្រុកព្រះស្តេច លេខ ១៨៨ ឆ្នាំ ១៩៩៥ អយក.បត
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅនិងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយការិយាល័យអប់រំ យុវជន និងកីឡា ស្រុកព្រះស្តេច ខេត្តព្រៃវែង ផ្តាច់សាលាឧបសម្ព័ន្ធ អោយទៅជាសាលាបឋមសិក្សាពេញលក្ខណៈ ÷

១-សាលាពោធិតាតន់ ជាឧបសម្ព័ន្ធសាលាវត្តកណ្តាល ឃុំអង្គរាជ ទៅជាសាលា បឋមសិក្សា«ពោធិតាតន់» ។

២-សាលាវត្តហារ ជាឧបសម្ព័ន្ធសាលាសិរីមានជ័យ ឃុំអង្គរាជ ទៅជាសាលាបឋមសិក្សា វត្តហារ ។

៣-សាលារតនស្វាយ ជាឧបសម្ព័ន្ធសាលាសទ្ធា ឃុំរំចេក ទៅជាសាលាបឋមសិក្សារតនស្វាយ ។

៤-សាលាពោធិរតនារាម ជាឧបសម្ព័ន្ធសាលាព្រះនរធំ ឃុំកំពង់សឹង ទៅជាសាលាបឋមសិក្សា«ពោធិរតនារាម» ។

៥-សាលាស្វាយ ជាឧបសម្ព័ន្ធសាលាប្រាសាទ ឃុំកំពង់សឹង ទៅជាសាលាបឋមសិក្សា ស្វាយ

៦-សាលាគោកសំពៅ ជាឧបសម្ព័ន្ធសាលាសិរីទួលក្លួណ៍ ឃុំក្រាំងល្វា ទៅជាសាលា បឋមសិក្សា គោកសំពៅ

៧-សាលាកគោ ជាឧបសម្ព័ន្ធសាលាសំពោង ឃុំបន្ទាយចក្រី ទៅជាសាលាបឋមសិក្សា

៨-សាលាដូនស្តើង ជាឧបសម្ព័ន្ធសាលាធ្លក ឃុំសេនារាជឧត្តម ទៅជាសាលាបឋម សិក្សាដូនស្តើង

ប្រការ ២ : សាលាបឋមសិក្សាដែលមានរាយនាមខាងលើ ត្រូវដឹកនាំដោយនាយកសាលាមួយរូប និង នាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសាលាបឋមសិក្សា ។

ប្រការ ៣ : នាយក និង នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

ប្រការ ៤ : មន្ទីរ ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការ នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា មន្ទីរអប់រំ យុវជន និង កីឡាខេត្តព្រៃវែង ការិយាល័យអប់រំ-យុវជន និង កីឡា ស្រុកព្រះស្តេច និង សាលាបឋមសិក្សាដូច មានរាយនាមខាងលើមានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
តូល ឡោះ

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៣៤៤ អយក.ប្រក

* * * * *

ស្តីពីការផ្លាស់សាលាឧបសម្ព័ន្ធ មកជាសាលាបឋមសិក្សាពេញលក្ខណៈ

រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើប្រាស់ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ -៧-១៩៩៤
- បានឃើញក្រឹត្យច្បាប់ លេខ ៣០ ក្រច ចុះថ្ងៃទី ២០ -១១-១៩៨៦ ស្តីពី

ប្រព័ន្ធអប់រំចំនេះទូទៅ

- បានឃើញអនុក្រឹត្យ លេខ ១៩ អនក្រ ចុះថ្ងៃទី ២៥-១០-១៩៨៦ ស្តីពីការកំនត់បទដ្ឋាន ប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពនានារបស់ក្រសួងអប់រំ
- បានពិនិត្យលិខិតស្នើសុំ របស់ការិយាល័យអប់រំ យុវជន និងកីឡា ស្រុកកំពង់ត្របែក លេខ ១៩២.៩៤ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៤
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅនិងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយការិយាល័យអប់រំ យុវជន និង កីឡា ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ផ្លាស់សាលាឧបសម្ព័ន្ធ អោយទៅជាសាលាបឋមសិក្សាពេញលក្ខណៈ ÷

១-សាលាឧបសម្ព័ន្ធភូមិរោង ទៅជាសាលាបឋមសិក្សាភូមិរោង ក្នុងឃុំ ចាម

២-សាលាឧបសម្ព័ន្ធពោធិវង្ស ទៅជាសាលាបឋមសិក្សាពោធិវង្ស ក្នុងឃុំ ថ្កូវ

៣-សាលាឧបសម្ព័ន្ធគោក្រោក ទៅជាសាលាបឋមសិក្សាគោក្រោក ក្នុងឃុំគោកខ្ពក

ប្រការ ២ : សាលាបឋមសិក្សាដូចមានរាយនាមខាងលើ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក និង នាយករងមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

ប្រការ ៤ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការ-ហិរញ្ញកិច្ចនាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា មន្ទីរអប់រំយុវជន និង កីឡាខេត្តព្រៃវែង ការិយាល័យអប់រំ យុវជន និង កីឡា ស្រុកកំពង់ត្របែក និង សាលាបឋមសិក្សា ដូចមានរាយនាមខាងលើមានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តូច ឡោះ

រាជធានីភ្នំពេញ , ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៣៥៣ អយក.ប្រក

ស្តីពីការផ្លាស់សាលាឧបសម្ព័ន្ធមកជា

សាលាបឋមសិក្សាពេញលក្ខណៈ

* * * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១–១១–១៩៩៣-ស្តីពីកាតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–១៩៩៤
- បានឃើញក្រឹត្យច្បាប់ លេខ ៣០ ក្រច ចុះថ្ងៃទី ២០–១១–១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានឃើញអនុក្រឹត្យ លេខ ១៩ អនក្រ ចុះថ្ងៃទី ២៥–១០–១៩៨៦ ស្តីពីការកំនត់បទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពនានា
- បានពិនិត្យលិខិតរបស់ការិយាល័យអប់រំ យុវជន និង កីឡា ស្រុកព្រៃវែង លេខ ៣១២–៩៤ លស. ចុះថ្ងៃទី ២៥–១២–១៩៩៤
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយការិយាល័យអប់រំ យុវជន និង កីឡា ស្រុកព្រៃវែង ខេត្តព្រៃវែងផ្លាច់សាលាឧបសម្ព័ន្ធ អោយទៅជាសាលាបឋមសិក្សាពេញលក្ខណៈ ÷

១–សាលាព្រៃក តាម៉ុកឧបសម្ព័ន្ធសាលាព្រៃកចារ ទៅជាសាលាបឋមសិក្សាព្រៃក តាម៉ុក

២–សាលាពានរោង ឧបសម្ព័ន្ធ ព្រៃកជ្រាំង ទៅជាសាលាបឋមសិក្សាពានរោង

៣–សាលាជាខ្នាង ជាឧបសម្ព័ន្ធសាលាឫស្សីព្រឹក្ស ទៅជាសាលាបឋមសិក្សាជាខ្នាង

៤–សាលាវត្តត្រាច ជាឧបសម្ព័ន្ធអង្គរទ្រេត ទៅជាសាលាបឋមសិក្សាអង្គរទ្រេត

៥–សាលាសង្កែ ជាឧបសម្ព័ន្ធសាលាព្រែកសំរោង ទៅជាសាលាបឋមសិក្សាសង្កែ

៦–សាលាតាំប្រជីស ជាឧបសម្ព័ន្ធសាលាសិរីមង្គល ទៅជាសាលាបឋមសិក្សាតាំប្រជីស

៧–សាលាត្រពាំងចក ជាឧបសម្ព័ន្ធសាលាព្រហ្ញ៉ូត ទៅជាសាលាបឋមសិក្សាត្រពាំងចក

៨–សាលាស្វាយមង្គល ជាឧបសម្ព័ន្ធសាលាព្រហ្ញ៉ូត ទៅជាសាលាបឋមសិក្សាស្វាយមង្គល

៩–សាលាវត្តសិរីមង្គល ជាឧបសម្ព័ន្ធសាលាទឹកថ្លា ទៅជាសាលាបឋមសិក្សាសិរីមង្គល

១០–សាលាចចក ជាឧបសម្ព័ន្ធសាលាមេបុណ្យ ទៅជាសាលាបឋមសិក្សាចចក

១១–សាលាថ្នល់ជ័យ ជាឧបសម្ព័ន្ធសាលាខេយាក ទៅជាសាលាបឋមសិក្សាថ្នល់ជ័យ

១២–សាលាភ្នំគង់ជាឧបសម្ព័ន្ធសាលាមេបុណ្យ ទៅជាសាលាបឋមសិក្សាភ្នំគង់

ប្រការ ២ : សាលាបឋមសិក្សាដែលមានរាយនាមខាងលើនេះ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង ព្រមទាំងបុគ្គលិកផ្សេងៗ សមស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក និង នាយករងមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

ប្រការ ៤ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការ–ហិរញ្ញកិច្ច នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា មន្ទីរអប់រំយុវជន និង កីឡាខេត្តព្រៃវែង ការិយាល័យអប់រំ–យុវជន និង កីឡា ស្រុកព្រៃវែង និង សាលាបឋមសិក្សាដូចមានរាយនាមខាងលើមានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

តូល ឡោះ

៧_ទីស្តីការរដ្ឋមន្ត្រីក្រសួងគ្រប់គ្រង
បរិដ្ឋាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ ៥១១ ប្រ.ក.បស្ថ

ស្តីពីការទទួលស្គាល់ និង ប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ

****

រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-៧-១៩៩៣
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-១៩៩៤
- យោងសេចក្តីសំរេចលេខ ៥៦ ប្រក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ពិនិត្យតាមតំរូវការចាំបាច់របស់ការិយាល័យ

សំរេច

ប្រការ ១ : ទទួលស្គាល់ និង ប្រគល់ភារកិច្ចជូនលោក **អៀង សុវណ្ណនរ៉ា** អោយបំពេញការងារ នៅ ក្រសួងគ្រប់គ្រងបរិដ្ឋាន ។

ប្រការ ២ : ប្រាក់បៀវត្ស និង របបឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួនក្រសួងគ្រប់គ្រងបរិដ្ឋានជានាផ្គត់ផ្គង់បន្ត បន្ទាប់ពីមានវិញ្ញាបនប័ត្រផ្តាច់ប្រាក់ពីអង្គភាពដើម ។

ប្រការ ៣ : អគ្គនាយក ខុទ្ទកាល័យ អង្គភាពពាក់ព័ន្ធ និង សាមីខ្លួនត្រូវទទួលប ុ ការអនុវត្តន៍

I–អធិការដ្ឋាន

១–កញ្ញា មាស សោភ័ណ

I–នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស

១–កញ្ញា សេង សោភ័ណ

២–កញ្ញា អ៊ុច ចំនូនារី

៣–អ្នកស្រី អ៊ុច រ៉ាវី

៤–លោក យិន ម៉ានី

៥–លោក ហង់ រិន

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួនទាំង ០៦ រូបខាងលើ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានភារកិច្ចរៀបចំជូនទៅតាមមុខងារចាប់ពី ថ្ងៃទី ០១–៨–១៩៩៥ ។

ប្រការ ៣ : ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋានផែនការ–គណនេយ្យ–ហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ ក្នុងប្រទេស និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ យុន

៩_ទីស្តីការក្រសួងធម្មការ និងសាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៩៥

សេចក្តីសម្រេច លេខ : ១៧៣/៩៥ ក.ធ.ស

ស្តីពីការទទួលស្គាល់ «ក្រុមប្រឹក្សាបរិស័ទគ្រិស្តនៃ

ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

បណ្ឌិត ម៉ុក ម៉ារ៉េត

៨_ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១០៧ បន.ប្រក

ស្តីពីការបញ្ចូលក្របខ័ណ្ឌ មន្ត្រី បុគ្គលិក រាជការ

* * * * * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ៤៨១ ម.ស.ក្រ.ខ ចុះថ្ងៃទី ០១-៧-១៩៩៥ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : បញ្ចូល និងចាត់តាំងបុគ្គលិករាជការ ចំនួន ០៦ រូប ដូចមានឈ្មោះខាងក្រោម អោយទៅបំរើការងារនៅក្នុងក្របខ័ណ្ឌអធិការដ្ឋាន នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស ក្នុងឋានៈជាបុគ្គលិក នៅស្គេលជា E 10B ÷

អោយបានម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា សន្សំជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់សង្គម ។

ប្រការ ៥ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសម្រេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

ប្រការ ៦ : នាយកដ្ឋានសាសនា និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធត្រូវសហការអនុវត្តន៍សេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៧ : សេចក្តីសម្រេចនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង វណ្ណារ័ត្ន

គណៈនិកាយសេវេនដេយ អាត់វេនទីស្ទ

នៅព្រះរាជាណាចក្រកម្ពុជា

* * * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងទី២ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី និង រដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាល របស់ព្រះរាជាណាចក្រកម្ពុជា
- បានឃើញលិខិតស្នើសុំទទួលស្គាល់ របស់គ្រិស្តបរិស័ទគណៈនិកាយសេវេនដេយអាត់វេនទីស្ទ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ទទួលស្គាល់ក្រុមប្រឹក្សាបរិស័ទគ្រិស្តនៃគណៈនិកាយសេវេនដេយ អាត់វេនទីស្ទជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : ក្រុមប្រឹក្សាបរិស័ទគ្រិស្តនៃគណៈនិកាយសេវេនដេយ អាត់វេនទីស្ទត្រូវគោរពតាមលក្ខន្តិកៈរបស់និកាយនេះដែលមានតំកល់ទុកនៅក្រសួង រាល់ការកែប្រែលក្ខន្តិកៈថ្មីត្រូវមានការឯកភាពពីក្រសួង ។

ប្រការ ៣ : ក្រុមប្រឹក្សាបរិស័ទគ្រិស្ត នៃគណៈនិកាយ សេវេនដេយ អាត់វេនទីស្ទ ត្រូវសហការអោយបានល្អជាមួយអង្គភាពពាក់ព័ន្ធ ករណីមានការផ្លាស់ប្តូរសមាសភាពដឹកនាំត្រូវមានការ ជូនដំណឹងមកក្រសួង ។

ប្រការ ៤ : ក្រុមប្រឹក្សាបរិស័ទគ្រិស្ត នៃគណៈនិកាយ សេវេនដេយ អាត់វេនទីស្ទ ត្រូវគោរព

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១៦៦៦ រៀល